**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ០៣ សរណន

# សារាចរណែនាំ
# ស្តីពី
# ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៣-២០២៥

## ១-សេចក្តីផ្តើម

មាត្រា ៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈបានចែងថា ប្រតិទិនសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ចែកជា ៣ ដំណាក់កាលៈ **ដំណាក់កាលទី ១** គឺការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ចាប់ពីខែ មីនា ដល់ខែ ឧសភា, **ដំណាក់កាលទី ២** គឺការរៀបចំកញ្ចប់ថវិកា ចាប់ពីខែ មិថុនា ដល់ខែ កញ្ញា និង**ដំណាក់កាលទី ៣** គឺការអនុម័តថវិកា ចាប់ពីខែ តុលា ដល់ខែ ធ្នូ។ ក្នុងបរិការណ៍ដែលស្ថានភាពភូមិសាស្ត្រនយោបាយមានការប្រែប្រួលយ៉ាងឆាប់រហ័ស ដែលបង្កើតឱ្យមានភាពមិនប្រកដប្រជាខ្ពស់ចំពោះចលនការងើបឡើងវិញផ្នែកសង្គម-សេដ្ឋកិច្ចតំបន់ និងសកលលោក ជាពិសេស ផលប៉ះពាល់ និងបញ្ច័យនៃការផ្ទុះឡើងនូវសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន ដែលបាន និងកំពុងបន្ទច់បង្អាក់ដល់ដំណើរការនៃនិម្មាបនកម្មសេដ្ឋកិច្ចតំបន់ និងសកល, រាជរដ្ឋាភិបាលបានសម្រេចរំកិលពេលវេលានៃការរៀបចំក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២៣ ពីខែ មីនា មកខែ ឧសភា និងរំកិលពេលវេលានៃការរៀបចំសារាចរណែនាំស្តីពីផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៣-២០២៥ មករៀបចំដំណាលគ្នាជាមួយនឹងការរៀបចំសារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣ ដែលត្រូវដាក់ចេញនៅសប្តាហ៍ទី១ នៃខែ មិថុនា នេះ។ ក្រោយពីបានតាមដានប្រកបដោយការយកចិត្តទុកដាក់ នូវការវាយតម្លៃរបស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗអំពីផលប៉ះពាល់នៃសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន មកលើស្ថានភាពសេដ្ឋកិច្ចសកល និងតំបន់, រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣ ដែលផ្តល់ជាមូលដ្ឋានដល់គ្រប់ក្រសួង-ស្ថាប័នរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៣-២០២៥ និងការលើកគម្រោងថវិកាប្រចាំឆ្នាំ ២០២៣។

ផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ, រាជរដ្ឋាភិបាលត្រូវដាក់ចេញសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២១-២០២៣ ដើម្បីផ្តល់គោលការណ៍ណែនាំថ្មីៗ និងមគ្គុទ្ទេសបច្ចេកទេសគន្លឹះៗ សម្រាប់គ្រប់ក្រសួង-ស្ថាប័នធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រថវិកា (៣ ឆ្នាំរំកិល) ដែលពេលនេះ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល

ដែលស្ថិតក្រោមក្រសួង-ស្ថាប័ននីមួយៗ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវរៀបចំ។ ដោយឡែក ចំពោះការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងមានសារាចរណែនាំដោយឡែកមួយផ្សេងទៀតស្របតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១។

ផែនការយុទ្ធសាស្ត្រថវិកា គឺជាឧបករណ៍ដ៏សំខាន់សម្រាប់៖ (១)-ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន និងគោលនយោបាយរបស់រាជរដ្ឋាភិបាល, (២)-បង្កើនវិចារណកម្មអាទិភាពចំណាយឱ្យកាន់តែឆ្លើយតបទៅនឹងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន, (៣)-ធានានិរន្តរភាពនៃការអនុវត្តកម្មវិធីរបស់ក្រសួង-ស្ថាប័ន ដើម្បីសម្រេចគោលបំណងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ (៤)-ជាមូលដ្ឋានសម្រាប់ការពន្យល់ និងការបង្ហាញសេចក្តីសំអាងអំពីតម្រូវការថវិកាសម្រាប់អនុវត្តគោលនយោបាយ និង (៥)-ជាមូលដ្ឋានសម្រាប់ការរៀបចំ និងវិភាជថវិកាប្រចាំឆ្នាំឱ្យចំគោលដៅអាទិភាព។ ដូច្នេះ ផែនការយុទ្ធសាស្ត្រថវិកាត្រូវតែឆ្លុះបញ្ចាំងឱ្យឃើញច្បាស់អំពីគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័នសាមីនីមួយៗ, អំពីកម្មវិធី, អំពីសូចនាករ និងគោលដៅសូចនាករសម្រាប់វាស់វែងលទ្ធផលនៃការអនុវត្តកម្មវិធីសមស្របនឹងទំហំថវិកា និងលទ្ធភាពថវិកាដែលមាន ដើម្បីរួមចំណែកសម្រេចគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ក្នុងន័យនេះ ក្រសួង-ស្ថាប័នមួយត្រូវមានផែនការយុទ្ធសាស្ត្រថវិការួមមួយដែលគ្របដណ្តប់ទាំងថវិការដ្ឋបាលកណ្តាល, ថវិកាមន្ទីរជំនាញរាជធានី-ខេត្ត និងថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្ថិតក្រោមឱវាទក្រសួង-ស្ថាប័ននោះ ព្រមទាំងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ)។

ទន្ទឹមនេះ ផែនការយុទ្ធសាស្ត្រថវិកា ក៏ជាឧបករណ៍សំខាន់សម្រាប់ធ្វើសមាហរណកម្មថវិកាចរន្ត និងថវិកាមូលធន ព្រមទាំងរវាងថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីធ្វើឱ្យផែនការយុទ្ធសាស្ត្រថវិកាមានគុណភាពកាន់តែល្អប្រសើរ ក៏ដូចជាជួយលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជ និងគ្រប់គ្រងថវិកាប្រចាំឆ្នាំ។ ជាមួយគ្នានេះ, ក្រសួង-ស្ថាប័ននីមួយៗត្រូវយកចិត្តទុកដាក់លើការកែលម្អគុណភាពផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៣-២០២៥ ដោយធានាការផ្សារភ្ជាប់ថវិកាទៅនឹងអាទិភាពគោលនយោបាយដែលកំណត់នៅក្នុង **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣**។ ដូចនេះ *ក្រសួង-ស្ថាប័ននីមួយៗ ត្រូវជំរុញ និងលើកទឹកចិត្តដល់ក្រុមការងារថវិការបស់ខ្លួនដែលមានសមាសភាពមកពីអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ឬ/និងថវិកា/គណនេយ្យ ដែលហៅថា "អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ", អគ្គនាយកដ្ឋាន/នាយកដ្ឋានផែនការ, អង្គភាពថវិកា/អង្គភាពជំនាញ និងអង្គភាពគ្រប់គ្រងគម្រោងឱ្យដំណើរការដោយសកម្ម និងប្រកបដោយ-ការទទួលខុសត្រូវខ្ពស់។*

ក្នុងន័យនេះ ក្រុមការងារថវិកាត្រូវខិតខំធានាឱ្យប្រាកដថា ទាំងធនធាន និងទាំងសកម្មភាពការងារទាំងអស់របស់ក្រសួង-ស្ថាប័នខ្លួន ត្រូវបានដាក់បញ្ចូល ឬឆ្លុះបញ្ចាំងក្នុងផែនការយុទ្ធសាស្ត្រថវិកា សំដៅធានាថាថវិកាត្រូវបានវិភាជត្រង់ទៅចំសកម្មភាព និងចំសេចក្តីត្រូវការយ៉ាងពិតប្រាកដរបស់អង្គភាពអនុវត្តសកម្មភាពរៀងៗខ្លួន ព្រមទាំងធានាបាននូវតុល្យភាពនៃការវិភាជថវិកា ហើយឆ្លើយតបបានជាអតិបរមាទៅនឹងគោលបំណងគោលនយោបាយ និងរវាងកម្មវិធីដែលបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា។ ដូចឆ្នាំកន្លងមកផងដែរ ក្រសួង-ស្ថាប័ននីមួយៗ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្តល់កិច្ចសហការល្អរវាងគ្នាទៅវិញទៅមក ដោយអនុញ្ញាតឱ្យ **ក្រុមការងារថវិកា** នៃក្រសួង-ស្ថាប័នសាមីមានភាពជាម្ចាស់ ក្នុងការធ្វើការងារជាមួយមន្ត្រីជំនាញថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **ដើម្បីពិនិត្យនិងកែលម្អកម្មវិធី ជាពិសេសយកចិត្តទុកដាក់កែលម្អសូចនាករសមិទ្ធកម្ម នៅកម្រិតកម្មវិធី អនុកម្មវិធី**

និងចង្កោមសកម្មភាព ក្នុងគោលបំណងដើម្បីបង្កើនគុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ក៏ដូចជាប្រសិទ្ធភាពក្នុងការរៀបចំផែនការថវិកាប្រចាំឆ្នាំ។

ស្របតាមទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥, ក្របខ័ណ្ឌថវិការយៈពេលមធ្យម (ក.ថ.ម) ត្រូវបានដាក់អនុវត្តសាកល្បង ដើម្បីផ្តល់កញ្ចប់ថវិកាក្នុងកម្រិតពិតានចំណាយគោលមួយដល់គ្រប់ក្រសួង-ស្ថាប័ន ដូចមានលម្អិត នៅក្នុងផ្នែក២.៣ សម្រាប់រៀបចំផែនការផែនការយុទ្ធសាស្ត្រថវិកា ដែលជាផែនការថវិការយៈពេលមធ្យម (៣ ឆ្នាំរំកិល) ទៅតាមរចនាសម្ព័ន្ធកម្មវិធី និងគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ននីមួយៗ ហើយដែលនឹងរួមចំណែកសម្រេចអាទិភាពគោលនយោបាយតាមវិស័យ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ក្រសួង-ស្ថាប័នត្រូវធ្វើផែនការថវិការយៈពេលមធ្យម ដោយគោរពតាមពិតានចំណាយគោលដែលបានផ្តល់ជូនសម្រាប់សកម្មភាពការងារ ឬគម្រោងដែលត្រូវបន្តអនុវត្តក្នុងក្របខ័ណ្ឌដែលមិនមានការផ្លាស់ប្តូរខាងអាទិភាពគោលនយោបាយ។ ជាមួយគ្នានេះ ក្រសួង-ស្ថាប័នត្រូវបានអនុញ្ញាតឱ្យគ្រោងនូវតម្រូវការធនធានថវិកាសម្រាប់អនុវត្តគោលនយោបាយថ្មីៗ ដែលទើបមានការសម្រេចពីរាជរដ្ឋាភិបាលនៅក្នុងឆ្នាំអនុវត្តថវិកានេះ។

ជារួម ដើម្បីជួយដល់ក្រសួង-ស្ថាប័ន មានមូលដ្ឋានក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៣-២០២៥ ឱ្យកាន់តែមានភាពជាក់ស្តែង រាជរដ្ឋាភិបាលដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយ ក៏ដូចជា ធ្វើការណែនាំដល់គ្រប់ក្រសួង-ស្ថាប័នទាំងអស់ នៅក្នុងផ្នែកបន្តបន្ទាប់ខាងក្រោមនេះ។

## ២-ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣ បានផ្តល់ទស្សនៈវិស័យរយៈពេលមធ្យមនៃការអភិវឌ្ឍសេដ្ឋកិច្ច និងកំណត់អាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល ព្រមទាំងនិន្នាការចំណូល និងចំណាយថវិកាជាតិសម្រាប់រយៈពេលមធ្យម ២០២៣-២០២៥ ក៏ដូចជាផ្តល់នូវលំហថវិការួមសម្រាប់ដោះស្រាយតម្រូវការចំណាយរបស់គ្រប់ក្រសួង-ស្ថាប័ន សម្រាប់រយៈពេលខ្លី និងមធ្យមរបស់ខ្លួន។ ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ក៏កំណត់ផងដែរអំពីលទ្ធភាពផ្នែកធនធាន និងអាទិភាពគោលនយោបាយចម្បងៗ ដើម្បីសម្រេចគោលដៅរួមរបស់រាជរដ្ឋាភិបាល។ ដូចនេះអាចនិយាយបានថា នៅក្នុងដំណើរការនៃការរៀបចំផែនការថវិកា ការកំណត់ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គឺជាយន្តការពីលើចុះក្រោម ចំណែកឯការរៀបចំផែនការយុទ្ធសាស្ត្រថវិកា គឺជាយន្តការពីក្រោមឡើងលើ។ យន្តការទាំងពីរនេះ គឺមានភាពចាំបាច់មិនអាចខ្វះបានដើម្បីធានាប្រសិទ្ធភាព និងភាពប្រាកដប្រជាអំពីលទ្ធភាពថវិកា និងការរៀបចំច្បាប់ថវិកាប្រចាំឆ្នាំ។

ក្នុងន័យនេះ រាជរដ្ឋាភិបាលសូមគូសរំលេចនូវខ្លឹមសារស្នូលនៃក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដូចខាងក្រោម៖

### ២.១-ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

ស្របគ្នានឹងការព្យាករសេដ្ឋកិច្ចសកលឡើងវិញ, សេដ្ឋកិច្ចកម្ពុជា ត្រូវបានរំពឹងថានឹងបន្តនិន្នាការកើនឡើងក្នុងអត្រា ៥,៤% ក្នុងឆ្នាំ ២០២២ ដែលបន្តគាំទ្រដោយភាពល្អប្រសើរនៃតម្រូវការសកល បើទោះបីជារងការប៉ះទង្គិច

ពីការផ្ទុះឡើងនៃសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែនយ៉ាងណាក្តី។ សង្គ្រាមនេះបានបង្កផលប៉ះពាល់ដោយប្រយោល ដល់សេដ្ឋកិច្ចកម្ពុជា តាមរយៈការកើនឡើងថ្លៃទំនិញគ្រប់ប្រភេទ ពិសេសប្រេងឥន្ធនៈ និងវត្ថុធាតុដើមកសិកម្ម រួមមានៈ ជី និងថ្នាំសម្លាប់សត្វល្អិត ជាដើម។ ទន្ទឹមនេះ, ការកើនឡើងថ្លៃជារួម បានបង្កផលប៉ះពាល់ដល់ សកម្មភាពចាយវាយ និងប្រើប្រាស់ក្នុងស្រុក ក៏ដូចជាជីវភាពរស់នៅរបស់ប្រជាជន (High Cost Of Living)។ ទោះជាយ៉ាងនេះក្តី, ផលប៉ះពាល់នៃសង្គ្រាមនេះមកលើសេដ្ឋកិច្ចកម្ពុជា គឺមានទំហំតូច ដោយហេតុថាទំនាក់ទំនង សេដ្ឋកិច្ចដោយផ្ទាល់រវាងកម្ពុជាជាមួយនឹងប្រទេសជម្លោះទាំងពីរមានកម្រិតទាប។ ផលប៉ះពាល់នេះត្រូវបានប៉ះប៉ូវ មកវិញមួយផ្នែកធំ តាមរយៈការសម្រេចបាននូវអត្រាខ្ពស់នៃការចាក់វ៉ាក់សាំងកូវីដ-១៩ ដែលបានធ្វើឱ្យកម្ពុជា បង្កើតបាននូវ **ភាពស៊ាំសហគមន៍** ជាមូលដ្ឋានសំខាន់សម្រាប់ការបើក ប្រទេសឡើងវិញ និងបានអនុញ្ញាតឱ្យ សកម្មភាពសេដ្ឋកិច្ចក្នុងស្រុកចាប់ផ្តើមវិលត្រឡប់ទៅរកប្រក្រតីភាពវិញ។ បន្ថែមលើនេះ, ការបន្តដាក់ចេញនូវ វិធានការអន្តរាគមន៍ មុតស្រួចរបស់រាជរដ្ឋាភិបាលក្នុងការជួយរក្សាលំនឹងធុរកិច្ច និងជីវភាពរស់នៅរបស់ប្រជាជន ជាពិសេសកម្មករ-និយោជិត និងគ្រួសារក្រីក្រ និងជនងាយរងគ្រោះ ដែលទទួលរងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩ ក៏រំពឹងថានឹងបន្តចូលរួមចំណែកទ្រទ្រង់កំណើនសេដ្ឋកិច្ចជារួម សម្រាប់ឆ្នាំ ២០២២។

សម្រាប់ឆ្នាំ ២០២៣, សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថានឹងសម្រេចបានអត្រាកំណើនក្នុងរង្វង់ ៦,៦% ដោយសារការរំពឹងទុកនៃការបន្តនិន្នាការល្អប្រសើរនៃតម្រូវការសកល និងទំនុកចិត្តវិនិយោគ ស្របពេលដែលវិបត្តិ ជំងឺកូវីដ-១៩ មានភាពស្រាកស្រាន្ត និងអាចគ្រប់គ្រងបាន។ ទន្ទឹមនេះ, **"ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារនិង ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ ២០២១- ២០២៣"** នឹងបន្តរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញ និងការបង្កើនតម្លៃបន្ថែមទៀត ដល់អនុវិស័យជំរុញកំណើន ដែលមានស្រាប់ ក៏ដូចជាលើកកម្ពស់អនុវិស័យសក្តានុពលដែលជាចន្លុះកំណើនថ្មី រួមមានៈ អនុវិស័យកម្មន្តសាល មិនមែនកាត់ដេរ និងអនុវិស័យគមនាគមន៍ ព្រមទាំងការអភិវឌ្ឍវិស័យសហគ្រាសធុនតូច និងមធ្យម។ ជាមួយគ្នានេះ, រាជរដ្ឋាភិបាលបានគិតគូរបង្កើនកញ្ចប់អន្តរាគមន៍ ជាពិសេសផ្នែកសង្គម និងសេដ្ឋកិច្ច ដើម្បីជួយកាត់បន្ថយ ផលប៉ះពាល់ពីការកើនឡើងអតិផរណា និងការបង្កើនការវិនិយោគក្នុងស្រុក ដើម្បីលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច និងបង្កើតការងារជូនប្រជាជនផងដែរ។ ជារួម, សេដ្ឋកិច្ចកម្ពុជាមានសក្តានុពលខ្ពស់ ក្នុងការសម្រេចបាននូវកំណើន រឹងមាំប្រកបដោយចីរភាពក្នុងរយៈពេលមធ្យមខាងមុខ ដោយសារការកែសម្រួលឡើងវិញជាយុទ្ធសាស្ត្រនូវខ្សែច្រវាក់ ផ្គត់ផ្គង់ និងតម្លៃតំបន់ និងសកល តាមរយៈការធ្វើពិពិធកម្មមូលដ្ឋានផលិតកម្ម (Reshoring and Relocation) សំដៅធានានិរន្តរភាពនៃខ្សែច្រវាក់ផលិតកម្ម ដែលបាននិងកំពុងផ្តល់ឱកាសសម្រាប់តំបន់អាស៊ាន រួមទាំង កម្ពុជា ក្នុង ការទទួលបានវិនិយោគបន្ថែម ដើម្បីទ្រទ្រង់កំណើនផងដែរ។ លើសពីនេះ, ការចាប់ផ្តើមអនុវត្តច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា ក៏នឹងជួយធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគ និងជំរុញដល់ការទាក់ទាញ វិនិយោគបន្ថែម ជាពិសេសសម្រាប់ឧស្សាហកម្មដែលបម្រើដល់ការនាំចេញ។

ក្នុងឆ្នាំ ២០២២ អតិផរណាត្រូវបានប៉ាន់ស្មានថានឹងអាចកើនឡើងក្នុងរង្វង់ ៥,០% ដោយសារការកើន ឡើងខ្ពស់នៃថ្លៃប្រេងអន្តរជាតិ និងថ្លៃទំនិញផ្សេងៗទៀត បណ្តាលមកពីសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន។ សម្រាប់ ឆ្នាំ ២០២៣, អតិផរណាត្រូវបានរំពឹងថានឹងថមថយមកវិញក្នុងរង្វង់ ២,៥% ដោយសារការរំពឹងទុកនូវការវិល ត្រឡប់ទៅរកប្រក្រតីភាពវិញនៃថ្លៃប្រេង និងទំនិញផ្សេងៗទៀត ក៏ដូចជាសកម្មភាពសេដ្ឋកិច្ច។ អត្រាប្តូរប្រាក់ រំពឹងថានឹងស្ថិតក្នុងរង្វង់ជាមធ្យមប្រចាំឆ្នាំប្រមាណ ៤ ០៦៥ រៀល ក្នុងមួយដុល្លារអាម៉េរិក ក្នុងឆ្នាំ ២០២២ និង

ឆ្នាំ ២០២៣ ដោយសារអន្តរាគមន៍របស់ធនាគារជាតិនៃកម្ពុជាក្នុងការរក្សាស្ថិរភាពថ្លៃ និងទំនុកចិត្តពីសាធារ-ណជនលើការប្រើប្រាស់ប្រាក់រៀល។

ឱនភាពគណនីចរន្ត (រួមបញ្ចូលបង្វែរ) ត្រូវបានប៉ាន់ស្មានថានឹងរួមតូចមកវិញក្នុងទំហំប្រមាណ ២៦,៨% នៃ ផសស ក្នុងឆ្នាំ ២០២២ ធៀបនឹង ៤៥,៤% នៃ ផសស ឆ្នាំ ២០២១ ក្រោមការរំពឹងទុកនូវការត្រឡប់ទៅរកប្រក្រតីភាពនៃសមតុល្យពាណិជ្ជកម្ម ក្នុងខណៈដែលចំណូលពីភ្ញៀវទេសចរអន្តរជាតិ និងប្រាក់បញ្ញើពីក្រៅប្រទេស (remittance) ក៏ត្រូវបានរំពឹងថានឹងងើបឡើងវិញសន្សឹមៗ ស្របតាមភាពស្រាកស្រាន្តនៃស្ថានភាពនៃវិបត្តិជំងឺកូវីដ-១៩ជាបណ្តើរៗ។ សម្រាប់ឆ្នាំ ២០២៣, ឱនភាពគណនីចរន្តរំពឹងថានឹងបន្តរួមតូចក្នុងរង្វង់ ១៤,១% នៃ ផសស ដោយសារការរំពឹងទុកនូវការបន្តកើនឡើងនៃការនាំចេញ និងការបន្តនិន្នាការងើបឡើងនៃចំណូលពីភ្ញៀវទេសចរអន្តរជាតិ។ ជាមួយគ្នានេះ, លំហូរវិនិយោគផ្ទាល់ពីបរទេសសម្រាប់ឆ្នាំ ២០២២ និងឆ្នាំ ២០២៣ ត្រូវបានរំពឹងថានឹងងើបឡើងក្នុងរង្វង់ ១២,០% នៃ ផសស និង ១១,៦% នៃ ផសស រៀងគ្នា ដោយសារការបន្តកើនឡើងនូវទំនុកចិត្តវិនិយោគ ជាមួយនឹងបរិយាកាសកាន់តែអំណោយផលរបស់កម្ពុជា ក្នុងបរិការណ៍នៃការផ្លាស់ប្តូរកាន់តែលឿននូវខ្សែច្រវាក់ផលិតកម្ម និងផ្គត់ផ្គង់តំបន់ និងសកល ស្របពេលដែលវិបត្តិជំងឺកូវីដ-១៩ មានភាពស្រាកស្រាន្ត។ ជាលទ្ធផល, ទុនបម្រុងអន្តរជាតិសរុប ត្រូវបានរំពឹងថានឹងបន្តកើនឡើងដល់ ២១ ២៧១ និង ២២ ១៥៥ លានដុល្លារអាមេរិក ដែលធានាការនាំចូលបានប្រមាណ ៧,៧ និង ៧,៦ ខែ ក្នុងឆ្នាំ ២០២២ និងឆ្នាំ ២០២៣ រៀងគ្នា។

## ២.២-ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

ដើម្បីធានាការសម្រេចបាននូវទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ចរយៈពេលមធ្យម ស្របតាមទិសដៅគោលនយោ-បាយអាទិភាពរបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញក្នុង **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣**, ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២៣ កំណត់យកអាទិភាពសំខាន់ៗដូចខាងក្រោម៖

- បន្តពង្រឹងសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ,
- បន្តធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច ក្នុងរយៈពេលមធ្យមប្រកបដោយបរិយាប័ន្ន,
- បន្តស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឱ្យត្រឡប់ទៅរកកំណើនសក្តានុពល តាមរយៈការបន្តអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣,
- ជំរុញការអភិវឌ្ឍប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គម ដើម្បីលើកកម្ពស់សុខុមាលភាពសង្គម និងកសាងភាពធន់នៃសង្គមកម្ពុជា ដែលអាច ឆ្លើយតបទៅនឹងគ្រោះអាសន្ន ដែលអាចកើតមានជាយថាហេតុ,
- ជំរុញការអភិវឌ្ឍធនធានមនុស្ស ដោយការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសគ្រប់កម្រិត ដើម្បីផ្គត់ផ្គង់ពលករជំនាញប្រកបដោយផលិតភាពខ្ពស់ឱ្យបាន-គ្រប់គ្រាន់ និងឆ្លើយតបនឹងតម្រូវការទីផ្សារ,

- ដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ព្រមទាំងប្រាក់ ឧបត្ថម្ភមន្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងកម្រិតសមស្រប ដើម្បីលើកកម្ពស់ជីវភាពរស់នៅ ព្រមទាំងពង្រឹងសមត្ថភាពស្ថាប័ន និងគុណភាពនៃការផ្តល់សេវាសាធារណៈ,
- ដំឡើងប្រាក់សោធន និង កាត់បន្ថយគម្លាតនៃប្រាក់សោធនរវាងអ្នកចូលនិវត្តន៍ចាស់ និងថ្មី ជូនដល់អតីតមន្ត្រីរាជការស៊ីវិល និងអតីតកងកម្លាំងប្រដាប់អាវុធ,
- បន្តជំរុញការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធ,
- ជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការអភិវឌ្ឍបៃតង សំដៅជំរុញការតភ្ជាប់ក្នុងសេដ្ឋកិច្ច, គាំទ្រការធ្វើបរិវត្តកម្មឌីជីថល និងអភិវឌ្ឍប្រកបដោយចីរភាព, និង
- បន្តគាំទ្រការអភិវឌ្ឍនៃសហគ្រាសធុនតូច និងមធ្យម តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា, ការដាក់ចេញវិធានការលើកទឹកចិត្តដាក់លាក់ និងការកែលម្អបរិយាកាសធុរកិច្ច,
- ជានាជោគជ័យនៃការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិទី ៧ និងការធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី ១២ ឆ្នាំ ២០២៣ ព្រមទាំងការត្រៀមសម្រាប់ការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភានីតិកាលទី ៥។

ដើម្បីសម្រេចបានតាមគោលដៅនៃក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈខាងលើនេះ រាជរដ្ឋាភិបាលបានកំណត់គោលដៅសូចនាករគន្លឹះផ្នែកហិរញ្ញវត្ថុសាធារណៈសម្រាប់ឆ្នាំ ២០២៣ ដូចខាងក្រោម៖

- **ចំណូលក្នុងស្រុកសរុបសម្រាប់ឆ្នាំ** ២០២៣ ត្រូវគ្រោងសម្រេចឱ្យបាន ២១,៨៩% នៃ ផសស ក្នុងនោះចំណូលចរន្តក្នុងទំហំ ២១,៦៤% នៃ ផសស និងចំណូលមូលធនក្នុងទំហំ ០,២៥% នៃ ផសស។ ចំណូលចរន្តត្រូវបានគ្រោងកើនឡើង ១៧,០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០២២ ដែលក្នុងនោះថ្នាក់ជាតិត្រូវសម្រេចឱ្យបានប្រមាណ ១៩,៦៩% នៃ ផសស និងសម្រាប់ថ្នាក់ក្រោមជាតិ ១,៩៥% នៃ ផសស។ ដោយឡែក ការប្រមូលចំណូលពីអគ្គនាយកដ្ឋានពន្ធដារ ត្រូវគ្រោងសម្រេចឱ្យបាន ១១,០% នៃ ផសស, ចំណូលពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវគ្រោងសម្រេចឱ្យបាន ៨,៤៨% នៃ ផសស និងចំណូលមិនមែនសារពើពន្ធត្រូវគ្រោងសម្រេចឱ្យបាន ២,១៦% នៃ ផសស។
- **ចំណាយសរុបថវិការដ្ឋ**នៅឆ្នាំ ២០២៣ នឹងកំណត់ក្នុងរង្វង់ ២៩,៤៣% នៃ ផសស ក្នុងនោះ ចំណាយសរុបថវិកាថ្នាក់ជាតិ ២៧,៤៨% ផសស និងចំណាយសរុបថវិកាថ្នាក់ក្រោមជាតិ ២,៩៥% នៃ ផសស ដោយរួមបញ្ចូលទាំងការឧបត្ថម្ភធនដល់ថ្នាក់ក្រោមជាតិចំនួន ១,០០% នៃ ផសស។
  - **ចំណាយចរន្តថវិការដ្ឋ**ត្រូវកំណត់ក្នុងកម្រិត ១៧,៦៥% នៃ ផសស ដែលក្នុងនោះ៖
    - **ចំណាយបន្ទុកបុគ្គលិក** មានសមាមាត្រស្មើនឹង ៤៤,៤៥% នៃចំណាយចរន្តថវិការដ្ឋ ត្រូវជា ៧,៨៥% នៃ ផសស ដោយផ្តោតអាទិភាពទៅលើការដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការ ក្នុង

គោលដៅលើកកម្ពស់ជីវភាពរស់នៅ, បង្កើនផលិតភាពការងារ និងពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដោយឈរលើគោលការណ៍សមធម៌, គុណាធិបតេយ្យ និងចីរភាពថវិកា,

- **ចំណាយក្រៅបន្ទុកបុគ្គលិក** មានសមាមាត្រស្មើនឹង ៥៥,៥៥% នៃចំណាយចរន្តថវិការដ្ឋ ត្រូវជា ៩,៨១% នៃ ផសស ដោយផ្តោតអាទិភាពលើ៖ (១)-ការបន្តគាំពារ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដោយយក **មនុស្សជាអាទិភាពទី ១** ព្រមទាំងរៀបចំមូលដ្ឋានសង្គមកម្ពុជាឱ្យកាន់តែមានភាពធន់រឹងមាំ តាមរយៈការពន្លឿនការកែទម្រង់ក្នុងវិស័យអប់រំ, ការលើកកម្ពស់ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការពង្រឹងគុណភាព និងការពង្រីកវិសាលភាពនៃវិស័យសុខាភិបាល និងប្រព័ន្ធគាំពារសង្គម; និង(២)-ការសម្រេចឱ្យបាននូវរាល់គោលដៅអាទិភាពនៃរបៀបវារៈគោលរបស់រាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា នៅឆ្នាំ ២០២៣ ដែលជាឆ្នាំចុងក្រោយនៃអាណត្តិ។

- **ចំណាយមូលធន** ត្រូវបានគ្រោងបង្កើនដល់ប្រមាណជា ១១,៧៨% នៃ ផសស ដោយផ្តោតអាទិភាពលើ (១)- ការជំរុញវិស័យជាចន្ទល់កំណើនសេដ្ឋកិច្ច ស្របតាមការចង្អុលបង្ហាញ នៅក្នុង **ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ ២០២១-២០២៣**, (២)- ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធ ដែលរួមទាំងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពខ្ពស់, ហេដ្ឋារចនាសម្ព័ន្ធឌីជីថល និង បៃតង ដើម្បីជំរុញពិពិធកម្មសេដ្ឋកិច្ចលើកកម្ពស់ភាពប្រកួតប្រជែង និងផ្តល់សម្ទុះបន្ថែមដល់កិច្ចអភិវឌ្ឍន៍សង្គមកម្ពុជាបន្ទាប់ពីវិបត្តិនៃជំងឺកូវីដ-១៩,

**សរុបចំណាយថវិកាថ្នាក់ជាតិ** ដែលរួមបញ្ចូលទាំងហិរញ្ញប្បទានក្រៅប្រទេស ត្រូវបានគ្រោងវិភាជទៅតាមវិស័យដូចខាងក្រោម៖

- **វិស័យរដ្ឋបាលទូទៅ៖** ត្រូវបានគ្រោងប្រមាណ ១,៧៥% នៃ ផសស សំដៅបន្តគាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, ការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងការទូត ពិសេសការអនុវត្តយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ ២០២១-២០២៣ និងការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា;
- **វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ៖** ត្រូវបានគ្រោងប្រមាណ ៣,៩១% នៃ ផសស ដោយបន្តផ្តោតលើការគាំទ្រការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌, ការលើកកម្ពស់សុខុមាលភាព និងពង្រឹងសមត្ថភាពរបស់កងកម្លាំងប្រដាប់អាវុធ ក្នុងបុព្វហេតុជានាកិច្ចការពារជាតិ និងរក្សាសន្តិភាព និងស្ថិរភាពនយោបាយ;
- **វិស័យសង្គមកិច្ច៖** ត្រូវបានគ្រោងប្រមាណ ៨,២៥% នៃ ផសស សំដៅបន្តលើកកម្ពស់គុណភាព និងពង្រីកវិសាលភាពនៃការទទួលបានសេវាសុខាភិបាល, ពង្រឹងប្រព័ន្ធសុខភាពសាធារណៈដែលឆ្លើយតបនឹងគ្រោះអាសន្ននាពេលអនាគត, អនុវត្តយុទ្ធសាស្ត្រស្តីពីការរស់នៅតាមគន្លងប្រក្រតីភាពថ្មី ក្នុងបរិបទនៃជំងឺកូវីដ-១៩, បន្តវិនិយោគលើគោលនយោបាយលើកកម្ពស់ការអប់រំ, គាំទ្រដល់

ការអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ ២០១៦-២០២៥, គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ ២០១៧-២០២៥, និងគោលនយោបាយអាទិភាពផ្សេងទៀតលើផ្នែកសង្គមកិច្ច សាសនា វប្បធម៌ និងបរិស្ថាន ជាពិសេសការប្រែប្រួលអាកាសធាតុ;

- **វិស័យសេដ្ឋកិច្ច៖** ត្រូវបានគ្រោងប្រមាណ ៧,១១% នៃ ផសស ដោយផ្តោតសំខាន់លើការគាំទ្រដល់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម, ការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរផលិតស្បែកជើងនិងកាបូបកម្ពុជាឆ្នាំ ២០២២-២០២៧, យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក, គោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ឆ្នាំ ២០២០-២០៣០, ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាឆ្នាំ ២០២១-២០៣៥, គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជាឆ្នាំ ២០២២-២០៣៥, គោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ ២០២១-២០៣០, និងការអនុវត្តផែនទីចង្អុលផ្លូវស្តីពីផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ ឆ្នាំ ២០២០-២០២៥, ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាបឆ្នាំ ២០២១-២០៣៥ និងផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរីឆ្នាំ ២០២១-២០៣៥;
- **ចំណាយផ្សេងៗ៖** ត្រូវបានគ្រោងប្រមាណ ៦,៤៥% នៃ ផសស ដើម្បីធានាបាននូវលទ្ធភាពអន្តរាគមន៍ភ្លាមៗ ក្នុងការដោះស្រាយនូវបញ្ហាសង្គម-សេដ្ឋកិច្ច និងត្រៀមបម្រុងសម្រាប់ការអនុវត្តគោលនយោបាយនានា, ការឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ, ការវិភាជកញ្ចប់ថវិកាសម្រាប់ការរៀបចំព្រឹត្តិការណ៍ជាតិ និងអន្តរជាតិ និងកិច្ចការបន្ទាន់ចំពោះមុខរបស់រាជរដ្ឋាភិបាល រួមទាំងការបន្តធ្វើអន្តរាគមន៍ឆ្លើយតបទៅនឹងផលប៉ះពាល់នៃជំងឺកូវីដ-១៩ មានជាអាទិ៍ ៖ *ការបន្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់គ្រួសារក្រីក្រ (ក្រ ១ និង ក្រ ២) និង ការរៀបចំកម្មវិធីឧបត្ថម្ភសាច់ប្រាក់តែមួយលើកជូនគ្រួសារដែលមានជីវភាពកៀកនឹងបន្ទាត់ក្រីក្រ ដើម្បីទប់ទល់នឹងបញ្ហាអតិផរណា, ការបន្តអនុវត្តកម្មវិធីសាច់ប្រាក់ពលកម្ម, កម្មវិធីអន្តរាគមន៍លើផ្នែកបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ, ការធានាជោគជ័យនៃការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិទី ៧ និងការធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី ១២ ឆ្នាំ ២០២៣។*

*ដូចនេះ ដោយឈរលើមូលដ្ឋានក្របខ័ណ្ឌចំណូល និងចំណាយខាងលើ, អតិរេកថវិកាចរន្តសម្រាប់ឆ្នាំ ២០២៣ នឹងសម្រេចបានប្រមាណ ៣,៩៩% នៃ ផសស និងឱនភាពថវិកាសរុបនឹងមានទំហំ -៧,៥៤% នៃ ផសស។ ក្នុងក្របខ័ណ្ឌនេះ, ថវិកាឆ្នាំ ២០២៣ ដែលជាឆ្នាំចុងក្រោយនៃនីតិកាលទី៦ នៃរដ្ឋសភា មាន**ចរិតជាថវិកាវិក្រឹតកម្មចំគោលដៅ** ដោយឈរលើគោលការណ៍ប្រសិទ្ធភាពថវិកា សំដៅសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សំខាន់ៗ និងរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល ព្រមទាំងគាំទ្រដល់ការជំរុញកំណើនសេដ្ឋកិច្ច ស្របតាមទិសដៅជាយុទ្ធសាស្ត្រ ដែលបានដាក់ចេញនៅក្នុង "ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ ២០២១-២០២៣"។*

ដើម្បីធានាបាននូវការអនុវត្តទៅតាមគោលដៅខាងលើ និងដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ, ការគ្រោងថវិកាឆ្នាំ ២០២៣ និងឆ្នាំបន្តបន្ទាប់ ត្រូវរៀបចំឡើងឈរលើមូលដ្ឋានយុទ្ធសាស្ត្រ និងក្របខ័ណ្ឌនៃវិធានការ ដូចខាងក្រោម៖

**ក. វិធានការផ្នែកចំណូល**

ក.១-វិធានការផ្នែកចំណូលពន្ធដារ

វិធានការគន្លឹះដាក់លាក់សម្រាប់អនុវត្តក្នុងឆ្នាំ ២០២៣ ដើម្បីគាំទ្រសកម្មភាពនៃអាជីវកម្មក្នុងស្រុក និងរក្សាចីរភាពកំណើនចំណូល ដែលនឹងត្រូវអនុវត្តដោយអគ្គនាយកដ្ឋានពន្ធដារ រួមមាន៖

- បន្តអនុវត្តគោលនយោបាយលើកទឹកចិត្តនានានិងដាក់ចេញនូវវិធានការចាំបាច់បន្ថែមទៀតដល់វិស័យដែលបន្តរងផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩,
- ពង្រឹងការប្រមូលចំណូលតាមវិស័យដែលនៅមានសក្តានុពល ដូចជា វិស័យសំណង់, វិស័យទូរគមនាគមន៍, វិស័យរ៉ែ, វិស័យផលិតស្រាបៀរ, ភេសជ្ជៈ និងថ្នាំជក់ ជាដើម,
- ពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលពាក់ព័ន្ធនឹងអចលនទ្រព្យ ដោយធ្វើបច្ចុប្បន្នភាពព័ត៌មានអចលនទ្រព្យ, ពង្រឹងអនុលោមភាពនៃការបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់, និង ពង្រឹងការបង់ពន្ធប្រថាប់ត្រា ចំពោះការលក់ ឬផ្ទេរសិទ្ធិភាគហ៊ុននៅក្នុងកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋាននានា,
- ពង្រឹងការប្រមូលចំណូលពន្ធ ជាពិសេសអាករលើតម្លៃបន្ថែម លើការផ្គត់ផ្គង់ទំនិញឌីជីថល ឬសេវាឌីជីថល ដែលធ្វើប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក,
- បន្តកែលម្អ និងធ្វើឱ្យកាន់តែប្រសើរឡើងនូវមុខងារស្នូលទាំង ៣ រួមមាន E-registration, E-filling, និង E-payment ដោយប្រើប្រាស់ថ្នាលបច្ចេកវិទ្យារួម ដែលមានភាពប្រឡាក់ក្រឡា, ស្វ័យប្រវត្តិកម្មពេញលេញ និង ផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធ, និង
- ធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសដែលជំពាក់បំណុលពន្ធ និងពង្រឹងយន្តការតាមដាន និងតឹងទារបំណុលពន្ធ។

ក.២-វិធានការផ្នែកចំណូលគយ និងរដ្ឋាករ

វិធានការគន្លឹះ ដែលគ្រោងនឹងដាក់ឱ្យអនុវត្តក្នុងឆ្នាំ ២០២៣ ដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នឹងផ្តោតលើគោលដៅជាអាទិភាព ដូចខាងក្រោម ៖

- បន្តអនុវត្តវិធានការលើកទឹកចិត្តពន្ធគយ ព្រមទាំងដាក់ឱ្យអនុវត្តនូវវិធានការបន្ថែម ដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ច ជាពិសេសសម្រាប់សហគ្រាសធុនតូច និងមធ្យម,
- កែលម្អគោលនយោបាយពន្ធ និងអាករ សម្រាប់វិស័យអាទិភាព និងមុខទំនិញនានាឱ្យស្របតាមតម្រូវការចាំបាច់ និងការវិវឌ្ឍនៃមុខទំនិញទាំងនោះ,
- បន្តធ្វើសាមញ្ញកម្ម និងទំនើបកម្មនីតិវិធីគយ និងកិច្ចប្រតិបត្តិការគយផ្សេងទៀត ស្របតាមស្តង់ដារអន្តរជាតិ សំដៅបង្កើនគុណភាពនៃការផ្តល់សេវា និងភាពពេញចិត្តរបស់ធុរជន,

- បន្តបង្កើនចំនួនធុរជនមានអនុលោមភាពខ្ពស់ និងជំរុញការអនុវត្តកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចមានការអនុញ្ញាត ( Authorized Economic Operator- AEO ), និង
- ពង្រីកវិសាលភាពនៃការអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ ឈានទៅដំណាក់កាលទី ៣ និងតភ្ជាប់បញ្ជរតែមួយជាតិកម្ពុជាទៅនឹងបញ្ជរតែមួយអាស៊ាន។

**ក.៣-វិធានការផ្នែកចំណូលមិនមែនសារពើពន្ធ**

ដើម្បីបន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងទ្រព្យសម្បត្តិរដ្ឋ និងប្រមូលចំណូលពីប្រភពដែលមានសក្តានុពល, វិធានការគន្លឹះចាំបាច់ត្រូវបន្តអនុវត្ត រួមមាន៖

- ជំរុញការរៀបចំ និងដាក់ឱ្យអនុវត្ត ប្រកបដោយប្រសិទ្ធភាពនូវលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ,
- ជំរុញការដាក់ឱ្យអនុវត្ត និងពង្រីកវិសាលភាពប្រព័ន្ធគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ( SARMIS ) នៅរដ្ឋបាល ក្រុង ស្រុក ឃុំ សង្កាត់,
- ជំរុញការអនុវត្តការប្រមូលចំណូលពីឈ្នួលដីសម្បទានសេដ្ឋកិច្ច ដោយផ្អែកលើទំហំក្នុងកិច្ចសន្យាស្របតាមគោលការណ៍អនុញ្ញាតរបស់រាជរដ្ឋាភិបាល,
- ជំរុញការបង់ចំណូលដីសម្បទានសេដ្ឋកិច្ច និងធនធានរ៉ែ តាមរយៈប្រព័ន្ធអេឡិចត្រូនិក និងបង់ប្រាក់រំដោះឱ្យបានទៀងទាត់ ដោយមានការធ្វើអធិការកិច្ច ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងពិនិត្យកែសម្រួលអត្រាសួយសារលើតម្លៃធនធានរ៉ែ និងនីតិវិធីបង់សួយសារ,
- បន្តតាមដាន និងគ្រប់គ្រងចំណូលពីការជួលទ្រព្យសម្បត្តិរដ្ឋ តាមរយៈការពិនិត្យលើកិច្ចសន្យាជួលទ្រព្យសម្បត្តិរដ្ឋ ជាមួយក្រសួងសាមី និងស្ថាប័នពាក់ព័ន្ធ, និង
- ពង្រឹងយន្តការគណៈកម្មការអន្តរក្រសួង ដើម្បីទប់ស្កាត់កុំឱ្យមានបំណុលថ្មី និងពង្រឹងការតឹងទារបំណុល។

## ខ. វិធានការផ្នែកចំណាយ

ដើម្បីសម្រេចបាននូវគោលដៅរក្សាស្ថិរភាពសង្គម និងទ្រទ្រង់ដល់ការងើបឡើងវិញនូវកំណើនសេដ្ឋកិច្ច, រាជរដ្ឋាភិបាលចាំបាច់ត្រូវពង្រឹងទាំងប្រសិទ្ធភាពវិភាជន៍ និងទាំងប្រសិទ្ធភាពប្រតិបត្តិការ និងការឆ្លើយតបទៅនឹងទិសដៅគោលនយោបាយ និងកម្មវិធីកែទម្រង់នានា តាមរយៈវិធានការសំខាន់ៗក្នុងឆ្នាំ ២០២៣ ដូចខាងក្រោម៖

- បន្តដាក់ចេញនូវកញ្ចប់ថវិកាអន្តរាគមន៍ សំដៅធានាបាននូវលទ្ធភាពក្នុងការបន្តជំរុញកំណើនសេដ្ឋកិច្ច និងដោះស្រាយបញ្ហាដែលនៅបន្តសេសសល់ពីវិបត្តិជំងឺកូវីដ-១៩;
- តម្រង់ធនធានថវិកាលើវិស័យគន្លឹះ ដែលនឹងធានាឱ្យបានភាពធន់ ប្រកបដោយបរិយាបន្ន និងចីរភាព តាមរយៈការផ្តល់អាទិភាពទៅលើការពង្រឹងរដ្ឋបាលសាធារណៈ, ការអភិវឌ្ឍធនធានមនុស្ស, ការកសាងហេដ្ឋារចនាសម្ព័ន្ធទាំងរូបវន្ត និងឌីជីថល, និងការពង្រឹងប្រព័ន្ធគាំពារសង្គម, ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, ប្រព័ន្ធសុខាភិបាល និងវិស័យហិរញ្ញវត្ថុ;

- កំណត់លក្ខខណ្ឌជ្រើសរើសក្របខ័ណ្ឌថ្មី សម្រាប់ទាំងផ្នែកមន្ត្រីរាជការស៊ីវិល យោធិន នគរបាលជាតិ និងស្ថាប័នឯករាជ្យ ដែលត្រូវស្មើនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ឆ្នាំ ២០២២ និងតាមគោលការណ៍អាទិភាពរបស់រាជរដ្ឋាភិបាល;
- បន្តអនុវត្តគោលការណ៍ដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធក្នុងគោលដៅបង្កើនគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដោយឈរលើគោលការណ៍ប្រសិទ្ធភាព, សមធម៌, សង្គតិភាព, គុណាធិបតេយ្យ និងចីរភាពថវិកា;
- ជំរុញការអនុវត្តកម្មវិធីកំណែទម្រង់នានា និងគោលនយោបាយអាទិភាព និងបន្តតម្រង់ទិសការប្រើប្រាស់ធនធានថវិកាជាតិ ដើម្បីជំរុញក្បាលម៉ាស៊ីនកំណើន;
- បន្តពង្រឹងគុណភាព និងពង្រីកវិសាលភាពនៃសេវាសាធារណៈ;
- បន្តកែលម្អគុណភាព និងភាពគ្រប់ជ្រុងជ្រោយនៃផែនការយុទ្ធសាស្ត្រថវិកា ដោយពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយតាមវិស័យអាទិភាព និងបន្តពង្រឹងការផ្សារភ្ជាប់ផែនការលទ្ធកម្មជាមួយនឹងសំណើថវិកាប្រចាំឆ្នាំ;
- បន្តពង្រឹងការអនុវត្តថវិកាកម្មវិធីនៅគ្រប់ក្រសួង-ស្ថាប័ន (រួមបញ្ចូលរដ្ឋបាលរាជធានី-ខេត្ត) និងពង្រឹងគុណភាពព័ត៌មានសមិទ្ធកម្ម ដើម្បីចាប់ផ្តើមអនុវត្តថវិកាសមិទ្ធកម្ម តាមរយៈការអនុវត្តកិច្ចព្រមព្រៀងលើលទ្ធផលក្នុងឆ្នាំ និងការរៀបចំយន្តការសម្រាប់ធ្វើការវាយតម្លៃ និងការផ្តល់ព័ត៌មានពីសមិទ្ធកម្ម;
- បន្តអនុវត្តយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ដោយជំរុញការខ្ចីឱ្យអស់លទ្ធភាព ប៉ុន្តែសម្រាប់តែវិស័យអាទិភាព ដែលមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ជាពិសេសវិស័យបង្កើនផលិតភាពផលិតកម្ម ជំរុញការតភ្ជាប់ និងលើកកម្ពស់សមត្ថភាពប្រកួតប្រជែង; និង
- បន្តពង្រឹង និងពង្រីកការអនុវត្តប្រព័ន្ធ FMIS ដល់គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយចាប់ផ្តើមអនុវត្តស្វ័យប្រវត្តិកម្មចំណាយ និងដាក់អនុវត្តចំណាត់ថ្នាក់ថវិកាទាំង ៧។

## ២.៣-ក្របខ័ណ្ឌថវិការយៈពេលមធ្យមឆ្នាំ ២០២៣-២០២៥

ផ្អែកតាមក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០២៣-២០២៥ ដូចបានកំណត់ខាងលើ ពិតានចំណាយគោលតាមវិស័យត្រូវបានកំណត់ដូចតទៅ៖

-វិស័យរដ្ឋបាលទូទៅ ត្រូវបានគ្រោងប្រមាណ ១,៧៥%, ១,៦៩%, និង ១,៦២% នៃ ផសស សម្រាប់ឆ្នាំ ២០២៣, ២០២៤ និង ២០២៥ រៀងគ្នា,

-វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ត្រូវបានគ្រោងប្រមាណ ៣,៩១%, ៣,៩១%, និង ៣,៩២% នៃ ផសស សម្រាប់ឆ្នាំ ២០២៣, ២០២៤ និង ២០២៥ រៀងគ្នា,

-វិស័យសង្គមកិច្ច ត្រូវបានគ្រោងប្រមាណ ៨,២៥%, ៧,៧៩%, និង ៧,៨៤% នៃ ផសស សម្រាប់ឆ្នាំ ២០២៣, ២០២៤ និង ២០២៥ រៀងគ្នា,

-វិស័យសេដ្ឋកិច្ច ត្រូវបានគ្រោងប្រមាណ ៧,១១%, ៦,៤៧%, និង ៥,៧៦% នៃ ផសស សម្រាប់ឆ្នាំ ២០២៣, ២០២៤ និង ២០២៥ រៀងគ្នា,

ក្របខ័ណ្ឌពិតានចំណាយគោលកម្រិតវិស័យនេះ ត្រូវបានគិតបញ្ចូលទាំងចំណាយចរន្ត និងចំណាយមូលធន ទាំងលទ្ធភាពហិរញ្ញប្បទានដោយថវិកាជាតិ និងលទ្ធភាពហិរញ្ញប្បទានក្រៅប្រទេស ទាំងទ្វេភាគី និងពហុភាគី។ ក្នុងន័យនេះ, សម្រាប់ឆ្នាំ ២០២៣ ក្របខ័ណ្ឌថវិការយៈពេលមធ្យម (ក.ថ.ម) បានកំណត់**ពិតានចំណាយគោលផ្នែកចំណាយចរន្ត** ជូនដល់គ្រប់ក្រសួង-ស្ថាប័ន។ ដោយឡែក **ពិតានចំណាយគោលផ្នែកចំណាយមូលធនសម្រាប់គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាថ្នាក់ជាតិ និងដោយហិរញ្ញប្បទានក្រៅប្រទេស** ត្រូវបានកំណត់សម្រាប់ក្រសួង-ស្ថាប័នចំនួន ៩ រួមមាន៖ ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងមហាផ្ទៃ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងសុខាភិបាល, និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។ ការកំណត់ពិតានចំណាយគោលដល់កម្រិតក្រសួង-ស្ថាប័ន ធ្វើឡើងដើម្បីពង្រឹងគុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា, ការបន្តពង្រឹងវិន័យថវិកា, ការបង្កើនប្រសិទ្ធភាពចំណាយ និងការកែលម្អការវិភាជធនធានសាធារណៈជារួម។

នៅក្នុងការអនុវត្តនេះ, *ការកំណត់ពិតានចំណាយគោល (Baseline Ceiling)* ត្រូវបានជ្រើសរើសជាអភិក្រមនៃការអនុវត្ត ដើម្បីផ្តល់មូលដ្ឋានច្បាស់លាស់មួយក្នុងផ្តល់កញ្ចប់ថវិកា។ ពិតានចំណាយគោល "គឺជាកញ្ចប់ថវិកាដែលក្រសួង-ស្ថាប័នអាចនឹងទទួលបានសម្រាប់ប្រតិបត្តិការសកម្មភាពការងារ និងកម្មវិធីដែលមានលក្ខណៈជាប្រចាំ ដោយគិតគូរបញ្ចូលនូវកត្តាតម្រូវការ (demand driver) ប៉ុន្តែ ត្រូវបានកាត់ចេញនូវទំហំចំណាយនៃគោលនយោបាយ និង/ឬ សកម្មភាពមិនប្រចាំ **និង/ឬ លទ្ធភាពដែលត្រូវបានវាយតម្លៃថាមិនមានប្រសិទ្ធភាព**, ដោយឡែក ចំពោះចំណាយសម្រាប់ការកែលម្អផលិតភាពការងារ, ការលើកកម្ពស់ប្រសិទ្ធភាព និងការអនុវត្តគោលនយោបាយថ្មី នឹងផ្តល់ជូនបន្ថែមទៀតតាមលទ្ធភាពថវិកាជាក់ស្តែងក្នុងឆ្នាំនីមួយៗ ហើយកញ្ចប់ថវិកាទាំងនេះនឹងត្រូវសម្រេចតាមរយៈការពិភាក្សាចរចាថវិកាប្រចាំឆ្នាំ។ អភិក្រមនេះ នឹងត្រូវកែលម្អជាបណ្តើរៗរហូតដល់ឆ្នាំ ២០២៥ ដើម្បីប្រែក្លាយ ក.ថ.ម ឱ្យក្លាយជាក្របខ័ណ្ឌដែលធានាបាននូវធនធានហិរញ្ញវត្ថុ និងថវិកាកាន់តែច្បាស់លាស់សម្រាប់រយៈពេលមធ្យម សម្រាប់គាំទ្រដល់ការសម្រេចបានគោលបំណងគោលនយោបាយ។

តាមគោលការណ៍នេះ ***រូបមន្តពិតានចំណាយគោលផ្នែកចំណាយចរន្ត**សម្រាប់ផ្តល់ដល់ក្រសួង-ស្ថាប័ន* និងឧបត្ថម្ភធនគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបានគិតគូរគណនាដោយផ្អែកជាចម្បងលើថវិកាចំណាយប្រចាំនៃឆ្នាំថវិកា (ឆ្នាំ N) ដោយបូកបន្ថែមថវិកាសម្រាប់អនុវត្តគោលនយោបាយថ្មីដែលអនុម័តនៅឆ្នាំថវិកា (ឆ្នាំ N) និងត្រូវចាត់ទុកជាចំណាយប្រចាំសម្រាប់ឆ្នាំគ្រោងថវិកា (ឆ្នាំ N+1) ប៉ុន្តែត្រូវកាត់ចេញវិញនូវចំណាយមិនប្រចាំ។ បន្ទាប់ពីនេះ ថវិកាចំណាយប្រចាំនៃឆ្នាំថវិកា (ឆ្នាំ N) ត្រូវកាត់ចេញនូវថវិកាសម្រាប់អនុវត្តគោលនយោបាយដែលអនុម័តនៅឆ្នាំមុន (ឆ្នាំ N-1) ដែលមិនបានអនុវត្ត។ ដោយឡែក សមាសធាតុផ្សេងៗទៀត ដូចជា អត្រាប្រែប្រួលនៃប្រាក់បៀវត្ស កត្តាអតិផរណា និងកត្តាតម្រូវការ នឹងត្រូវសម្រេចដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយផ្អែកលើការប្រជុំពិភាក្សាជាមួយនឹងក្រសួង-ស្ថាប័ននីមួយៗ។ សរុបមក **ពិតានចំណាយគោលឆ្នាំ ២០២៣-២០២៥** ផ្តល់នូវការធានាធនធានហិរញ្ញវត្ថុ និងថវិកាជូនដល់គ្រប់ក្រសួង-ស្ថាប័ន ***ដូចដែលបានរៀបចំ និងមានភ្ជាប់ជូនក្នុងតារាង ១ និងឧបសម្ព័ន្ធ ១*** សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៣-២០២៥។

## ៣-រចនាសម្ព័ន្ធ និងគោលការណ៍នៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៣-២០២៥

ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ បានកំណត់គោលដៅរួមនៃការប្រមូលចំណូល ដោយបានដាក់ចេញនូវវិធានការចាំបាច់ និងជាក់ស្តែងដែលត្រូវអនុវត្តក្នុងឆ្នាំ ដើម្បីសម្រេចគោលដៅទាំងនេះ និងបានកំណត់គោលដៅរួមនៃការអនុវត្តចំណាយ និងដាក់ចេញអាទិភាពគោល-នយោបាយសំខាន់ៗ ដើម្បីសម្រេចគោលដៅរួមរបស់រាជរដ្ឋាភិបាល។ ដូច្នេះ ក្រសួង-ស្ថាប័ននីមួយៗត្រូវផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដូចបានកំណត់ខាងលើ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន ឱ្យបានល្អត្រឹមត្រូវតាមទិសដៅនេះ។ ទន្ទឹមនេះ ដើម្បីជាមូលដ្ឋានសម្រាប់ក្រសួង-ស្ថាប័ន អាចរៀបចំផែនការយុទ្ធសាស្ត្រថវិកាប្រកបដោយប្រសិទ្ធភាព និងមានលក្ខណៈឯកភាពគ្នាទាំងរចនាសម្ព័ន្ធ និងទាំងខ្លឹមសារ ផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង-ស្ថាប័ននីមួយៗត្រូវបានរៀបចំតាមទម្រង់ដូចខាងក្រោម៖

- ផ្នែកទី១៖ **អំពីសេចក្តីផ្តើម**

ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៣-២០២៥ របស់ក្រសួង-ស្ថាប័ននីមួយៗ ត្រូវបានរៀបចំឡើងដោយចាប់ផ្តើមគូសរំលេចអំពីតួនាទី និងបេសកកម្មរបស់ក្រសួង-ស្ថាប័ន, អំពីស្ថានភាពជាក់ស្តែងនៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២១-២០២៣ និងការប៉ាន់ស្មានស្ថានភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២២-២០២៤ ធៀបនឹងគោលដៅសូចនាករដែលបានកំណត់ និងលើកឡើងបញ្ហាប្រឈមដែលត្រូវដោះស្រាយក្នុងឆ្នាំ ២០២២ និងឆ្នាំខាងមុខ។ បន្ទាប់មកត្រូវបរិយាយរំលេចផងដែរ អំពីវិធានការគោលនយោបាយសំខាន់ៗដែលក្រសួង-ស្ថាប័នបានដាក់ចេញ រួមទាំងគោលនយោបាយតាមវិស័យ និងអន្តរវិស័យ។ **សូមរៀបចំខ្លឹមសារនៃផ្នែកទី ១ នេះ ទៅតាមទម្រង់គំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

- ផ្នែកទី២៖ **អំពីគោលបំណងគោលនយោបាយ**

គោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន ត្រូវបានរៀបចំ*ដោយផ្អែកលើយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤* និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣។ ទោះបី គោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ននីមួយៗ មិនមែនជាកម្មវត្ថុនៃការធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំ ប៉ុន្តែក្រសួង-ស្ថាប័នខ្លះ គួរពិនិត្យឡើងវិញនូវគោលបំណងគោលនយោបាយ ដោយផ្សារភ្ជាប់ទៅនឹងអាទិភាពគោល-នយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី ៦ នៃរដ្ឋសភា ដើម្បីធានាថាគោលនយោបាយនោះ គឺមានភាពត្រឹមត្រូវគ្រប់ជ្រុងជ្រោយ និងឆ្លើយតបកាន់តែច្បាស់លាស់ទៅនឹងគោលនយោបាយតាមវិស័យរបស់ខ្លួន និងគោលដៅរួមរបស់រាជរដ្ឋាភិបាល។ ជាគោលការណ៍រួម *ក្រសួង-ស្ថាប័ននីមួយៗត្រូវមានគោលបំណងគោលនយោបាយមិនលើសពី ២ ឡើយ* ក៏ប៉ុន្តែ ចំពោះ*ក្រសួង-ស្ថាប័នដែលមានមុខងារច្រើនវិស័យ អាចត្រូវបានអនុញ្ញាតឱ្យមានគោលបំណងគោលនយោបាយលើសពី ២* ប៉ុន្តែជាកម្មវត្ថុនៃការពិភាក្សា និងឯកភាពជាមុនពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ **សូមរៀបចំខ្លឹមសារនៃផ្នែកទី ២ នេះទៅតាមទម្រង់គំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

- ផ្នែកទី៣៖ **អំពីកម្មវិធី**

*ការរៀបចំកម្មវិធី ត្រូវឆ្លើយតបនឹងគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន និងត្រូវពណ៌នាអំពីគោលបំណងនៃកម្មវិធីនីមួយៗឱ្យបានច្បាស់លាស់ ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញច្បាស់ពីការផ្សារភ្ជាប់កម្មវិធីទៅនឹងគោលបំណងគោលនយោបាយ។* ដូច្នេះ នៅក្នុងផ្នែកនេះ *គ្រប់ក្រសួង-ស្ថាប័ន និងអង្គភាពថវិកាត្រូវពិនិត្យឡើងវិញ*

*នូវឈ្មោះកម្មវិធី និងអនុកម្មវិធី ព្រមទាំងកែសម្រួលឈ្មោះឱ្យកាន់តែខ្លី និងងាយយល់។ ក្រសួង-ស្ថាប័ន ត្រូវយកចិត្តទុកដាក់ក្នុងការផ្តល់ការពណ៌នាអំពីកម្មវិធី និងអនុកម្មវិធីឱ្យបានល្អ ដើម្បីជានាបាននូវការផ្សារភ្ជាប់ថវិកាទៅនឹងគោលបំណងគោលនយោបាយ ជាពិសេសត្រូវកំណត់សូចនាករ និងគោលដៅសូចនាករឱ្យបានត្រឹមត្រូវ និងច្បាស់លាស់* ***ដើម្បីចាប់ផ្តើមអនុវត្តសាកល្បងថវិកាព័ត៌មានសមិទ្ធកម្ម ឬហៅកាត់ថា "ថវិកាសមិទ្ធកម្ម" ព្រមជាមួយនឹងការចាប់ផ្តើមអនុវត្តសាកល្បងកិច្ចព្រមព្រៀងសមិទ្ធកម្ម ចាប់ពីឆ្នាំ ២០២៣ ដែលកិច្ចព្រមព្រៀងសមិទ្ធកម្មនេះ ត្រូវបានកំណត់ជា ៣ កម្រិត៖*** *(ទី១)- រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួង-ស្ថាប័នសាមី, (ទី២)- រវាងរដ្ឋមន្ត្រីក្រសួង-ស្ថាប័ន ជាមួយនឹងអ្នកគ្រប់គ្រងកម្មវិធីនៅតាមក្រសួង-ស្ថាប័ន សាមី, និង (ទី៣)- រវាងអ្នកគ្រប់គ្រងកម្មវិធីជាមួយនឹងប្រធានអង្គភាពថវិកា* ***ដូចមានភ្ជាប់ជូននូវគំរូកិច្ចព្រមព្រៀងសមិទ្ធកម្មទាំង ៣ កម្រិតនេះ***។

ស្របតាមគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាសមិទ្ធកម្ម ក្រសួង-ស្ថាប័នត្រូវបំពេញព័ត៌មានលម្អិតអំពីសូចនាករលទ្ធផលក្នុងឆ្នាំ និងសូចនាករលទ្ធផលចុងក្រោយ ដូចក្នុងទម្រង់ "ក" នៃ តារាង ២ "ក"។ ដូចនេះ, ក្នុងករណីក្រសួង-ស្ថាប័នស្នើសុំផ្លាស់ប្តូរ ឬធ្វើបច្ចុប្បន្នភាពលើរចនាសម្ព័ន្ធថវិកាសមិទ្ធកម្ម (រចនាសម្ព័ន្ធកម្មវិធី និងសូចនាករសមិទ្ធកម្ម) ដូចជា៖ ការបន្ថែម ការកែសម្រួល ឬការដកចេញនូវកម្មវិធីអនុកម្មវិធី ឬចង្កោមសកម្មភាព ក្រសួង-ស្ថាប័នត្រូវបំពេញទម្រង់ "ខ" នៃ តារាង ៤ "ក" ដោយត្រូវធ្វើការបញ្ជាក់ ឬពន្យល់អំពីមូលហេតុនៃការ-ផ្លាស់ប្តូរ និងត្រូវមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាចាំបាច់។ នៅពេលដែលមានការយល់ព្រមលើការផ្លាស់ប្តូររចនាសម្ព័ន្ធកម្មវិធី និងសូចនាករសមិទ្ធកម្ម ក្រសួង-ស្ថាប័នត្រូវបំពេញតារាងរចនាសម្ព័ន្ធថវិកាសមិទ្ធកម្មឡើងវិញដែលមានភ្ជាប់ជាទម្រង់ "គ" នៃ តារាង ៥ "ក" ដែលជាតារាងសមាសធាតុសង្ខេបនៃរចនាសម្ព័ន្ធថវិកាសមិទ្ធកម្ម។ ទម្រង់នេះ គឺជាផ្នែកមួយក្នុងការបង្ហាញពីអង្គភាព និងអ្នកទទួលខុសត្រូវរបស់កម្មវិធី និងអនុកម្មវិធី។

ជាមួយគ្នានេះ ក្រសួង-ស្ថាប័ននីមួយៗ ត្រូវគិតគូរដាក់បញ្ចូលក្នុងគម្រោងថវិកានូវបណ្តាអាទិភាពអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលមានចរិតជាអន្តរវិស័យ ដូចជា **គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម គោលនយោបាយេនឌ័រ និងការបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ ជាដើម**។ ចំពោះការគាំទ្រផ្នែកបច្ចេកទេសលើរបៀបរៀបចំគម្រោងថវិកាដែលទប់ទល់នឹងការប្រែប្រួលអាកាសធាតុ ក្រសួង-ស្ថាប័នពាក់ព័ន្ធអាចធ្វើទំនាក់ទំនងផ្ទាល់ជាមួយនឹងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពនៃក្រសួងបរិស្ថាន។ ជាគោលការណ៍រួម *ក្រសួង-ស្ថាប័ននីមួយៗ អាចមានកម្មវិធីមិនឱ្យលើសពី ៥ ឡើយ* ក៏ប៉ុន្តែចំពោះអនុកម្មវិធី អាចមានចំនួនសមស្របទៅតាមការចាំបាច់ ដែលបម្រើឱ្យគោលបំណងរួមនៃកម្មវិធីនីមួយៗ។ **ដោយឡែក សម្រាប់ក្រសួង-ស្ថាប័នធំៗ ដែលមានមុខងារច្រើន អាចត្រូវបានអនុញ្ញាតឱ្យមានកម្មវិធីលើសពី ៥ ប៉ុន្តែជាកម្មវត្ថុនៃការពិភាក្សា និង ឯកភាពជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ស្របតាមគោលការណ៍ដែលត្រូវបានកំណត់នៅក្នុងគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាសមិទ្ធកម្ម។

កម្មវិធី គឺជាឧបករណ៍ដែលបង្កើតឡើងដើម្បីឱ្យអគ្គនាយកដ្ឋាន និងអង្គភាពប្រហាក់ប្រហែល ក្រោមឱវាទរបស់ក្រសួង-ស្ថាប័ន ដាក់ចេញនូវ**អនុកម្មវិធី** និង**ចង្កោមសកម្មភាព** សម្រាប់ជាមូលដ្ឋាននៃការលើកគម្រោងថវិកាដើម្បីអនុវត្តកម្មវិធីនោះ ក្នុងគោលដៅសម្រេចគោលបំណងគោលនយោបាយដែលបានកំណត់នៅក្នុងផ្នែកទី ២។ គួរកត់សម្គាល់ថា ចង្កោមសកម្មភាពសំដៅលើសកម្មភាពចម្បងៗ ដែលអាចមានចំនួនសមស្របទៅតាមការចាំបាច់សម្រាប់បម្រើឱ្យគោលបំណងរួមនៃអនុកម្មវិធីនីមួយៗ ហើយចង្កោមសកម្មភាពមួយ អាចមានសកម្មភាពតូចៗមួយចំនួនដែលរួមចំណែកបង្កើតលទ្ធផលក្នុងឆ្នាំ (Output) សម្រាប់ចង្កោមសកម្មភាពនោះ។

កម្មវិធី ត្រូវមានខ្លឹមសារទូលាយ និងមានលក្ខណៈគ្របដណ្ដប់បានទាំងស្រុង គ្រប់តួនាទី ភារកិច្ច និងបេសកកម្មរបស់ក្រសួង-ស្ថាប័ននីមួយៗ ព្រមទាំងមានលក្ខណៈសមាហរណកម្មក្នុងកម្រិតវិស័យ ដោយត្រូវគ្របដណ្ដប់លើគម្រោង ឬសកម្មភាពការងារទាំងអស់ ទាំងគម្រោង ឬសកម្មភាពការងារដែលហិរញ្ញប្បទានដោយថវិការដ្ឋ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ ទាំងថវិកាចរន្ត និងថវិកាមូលធន។ ជាមួយគ្នានេះ ក្រសួង-ស្ថាប័នត្រូវកំណត់អង្គភាពទទួលខុសត្រូវ ដែលហៅថា **អង្គភាពថវិកា** និងអ្នកគ្រប់គ្រងទៅតាមកម្រិតនៃរចនាសម្ព័ន្ធកម្មវិធី (កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព)។

ដើម្បីពង្រឹងការអនុវត្ត ***អនុក្រឹត្យលេខ ២៤២ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០២១ ស្ដីពីការបង្កើនចំនួនអង្គភាពថវិកា និងការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនអង្គភាពថវិកា*** ប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់, នៅក្នុងអំឡុងពេលនៃការរៀបចំគម្រោងថវិកាឆ្នាំ ២០២៣ របស់ខ្លួននេះ ***ក្រសួង-ស្ថាប័នត្រូវដាក់ចេញនូវផែនការច្បាស់លាស់ក្នុងការបង្កើនចំនួនអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ សម្រាប់អនុវត្តនៅឆ្នាំ ២០២៣, ឆ្នាំ ២០២៤ និងឆ្នាំ២០២៥***។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងផ្ដល់កិច្ចសហការផ្នែកបច្ចេកទេសលើការពិនិត្យ និងវាយតម្លៃអំពីលក្ខណៈវិនិច្ឆ័យរបស់អង្គភាពដែលអាចនឹងត្រូវបង្កើតជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ ឬអង្គភាពថវិកា ដែលអាចនឹងប្រែក្លាយជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ ព្រមទាំងផ្ដល់ការបណ្ដុះបណ្ដាលសមត្ថភាពផ្នែកថវិកា និងនីតិវិធីហិរញ្ញវត្ថុ ដល់អង្គភាពថវិកា ទៅតាមការស្នើសុំពីក្រសួង-ស្ថាប័នសាមីនីមួយៗ។

ទន្ទឹមនេះ ក្នុងក្របខ័ណ្ឌនៃការកែទម្រង់ប្រព័ន្ធថវិកា ក្រសួង-ស្ថាប័ននីមួយៗ ត្រូវកំណត់ភារកិច្ច វិសាលភាពការងារ និងក្របខ័ណ្ឌទទួលខុសត្រូវរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល មន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ឱ្យច្បាស់លាស់នៅក្នុងរចនាសម្ព័ន្ធកម្មវិធី។ មន្ទីរជំនាញរាជធានី-ខេត្ត មិនចាំបាច់ត្រូវមានកម្មវិធីដោយឡែកទេ ព្រោះមន្ទីរជំនាញរាជធានី-ខេត្ត គឺជាដៃ ឬខ្សែបណ្ដោយរបស់ក្រសួង-ស្ថាប័ននៅតាមរាជធានី-ខេត្ត ដែលមានភារកិច្ចចូលរួមចំណែកអនុវត្តបណ្ដាកម្មវិធីរបស់ក្រសួង-ស្ថាប័ន។

ក្នុងន័យនេះ ក្រសួង-ស្ថាប័ននីមួយៗ ត្រូវណែនាំមន្ទីរជំនាញនៅរាជធានី-ខេត្តរៀងខ្លួន អំពីអនុកម្មវិធីរួមមួយនៅក្នុងកម្មវិធីនីមួយៗ ដោយផ្អែកលើមុខងារ វិសាលភាពការងារ និងលក្ខណៈដោយឡែកនៃគោលនយោបាយនិងសេវាសាធារណៈរបស់ក្រសួង-ស្ថាប័នរៀងខ្លួន ដើម្បីឱ្យមន្ទីរជំនាញរាជធានី-ខេត្តរបស់ខ្លួនដឹងច្បាស់អំពីទីតាំងនៃអនុកម្មវិធីរួមមួយនៅក្នុងកម្មវិធីនីមួយៗរបស់ក្រសួង-ស្ថាប័នរៀងខ្លួន។ ជាទូទៅ មន្ទីរជំនាញមួយអាចមានចង្កោមសកម្មភាពគាំទ្រគ្រប់កម្មវិធីរបស់ក្រសួង-ស្ថាប័ន ឬអាចមានចង្កោមសកម្មភាពគាំទ្រ ២ ទៅ ៣ ដោយផ្អែកតាមមុខងារ និងភារកិច្ចរបស់មន្ទីរជំនាញរាជធានី-ខេត្តនៃក្រសួង-ស្ថាប័ននីមួយៗ។ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) **ត្រូវរៀបចំផ្នែកទី ៣ នេះ ទៅតាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ**។

- **ផ្នែកទី៤៖ សូចនាករ និងគោលដៅសូចនាករ នៃសមិទ្ធកម្ម ឬលទ្ធផល**

គោលបំណងគោលនយោបាយ កម្មវិធី និងអនុកម្មវិធីនីមួយៗ ត្រូវមានសូចនាករសម្រាប់វាស់វែងលទ្ធផល ឬសមិទ្ធកម្ម ហើយត្រូវកំណត់គោលដៅសូចនាករលទ្ធផលដែលចង់សម្រេចបានសម្រាប់ជាមូលដ្ឋាននៃការត្រួតពិនិត្យ

តាមដាន និងវាយតម្លៃលទ្ធផលនៃការអនុវត្ត។ ក្នុងការកំណត់សូចនាករសម្រាប់ការវាស់វែងក្រសួង-ស្ថាប័ននីមួយៗ ត្រូវកំណត់ទាំងសូចនាករលទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយ។

សូចនាករលទ្ធផលក្នុងឆ្នាំ គឺជារង្វាស់ដែលបានជ្រើសរើសសម្រាប់វាស់លទ្ធផល/សមិទ្ធកម្មនៃការអនុវត្ត អនុកម្មវិធី ចង្កោមសកម្មភាព ទៅតាមគោលដៅដែលបានកំណត់ក្នុងរយៈពេលជាក់លាក់មួយដែលមិនលើសពីមួយឆ្នាំ។ រីឯសូចនាករលទ្ធផលចុងក្រោយ គឺជារង្វាស់ដែលបានជ្រើសរើសសម្រាប់វាស់លទ្ធផល/សមិទ្ធកម្មចុងក្រោយនៃកម្មវិធី។

ក្រសួង-ស្ថាប័ននីមួយៗ អាចកែលម្អសូចនាករតាមកម្រិតនៃរចនាសម្ព័ន្ធកម្មវិធីនីមួយៗ តាមរយៈការបន្ថែមសូចនាករថ្មី និងកែសម្រួលសូចនាករចាស់ដែលបានកំណត់កន្លងមក។ ការជ្រើសរើសសូចនាករនីមួយៗ ត្រូវមានការពន្យល់ពីមូលហេតុឱ្យច្បាស់លាស់។ ចំពោះសូចនាករចាស់ត្រូវបញ្ជាក់អំពីស្ថានភាពនៃការអនុវត្តឆ្នាំ ២០២១ ការព្យាករណ៍ស្ថានភាពនៃការអនុវត្តក្នុងឆ្នាំ ២០២២ និងធ្វើបច្ចុប្បន្នភាពតាមការជាក់ស្តែង។

**កម្មវិធីនីមួយៗ អាចមានសូចនាករលទ្ធផលចុងក្រោយយ៉ាងច្រើនចំនួន ៣ និងសូចនាករលទ្ធផលក្នុងឆ្នាំមួយចំនួន** ដើម្បីធានានូវការសម្រេចបានលទ្ធផលជាក់លាក់នៃការអនុវត្តកម្មវិធី។ ជារួម បន្ទាប់ពីការជ្រើសរើស និងកំណត់បាននូវសូចនាករសមស្របរួចហើយ ចាំបាច់ត្រូវកំណត់គោលដៅនៃសូចនាករ ទាំងគោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ និងគោលដៅសូចនាករលទ្ធផលចុងក្រោយ។ គោលដៅសូចនាករទាំងពីរប្រភេទនេះចាំបាច់ត្រូវឱ្យមានទំនាក់ទំនងគ្នា និងឆ្លើយតបគ្នាយ៉ាងមានប្រសិទ្ធភាព ដើម្បីធានានូវការសម្រេចបានលទ្ធផលនៃគោលបំណងគោលនយោបាយដែលបានកំណត់នៅក្នុងរយៈពេលជាក់លាក់មួយ។ **គោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ**មានលក្ខណៈជា**បរិមាណ** ឬ/និងជា**គុណភាពប្រចាំឆ្នាំ** ដែលជាសមិទ្ធកម្មនៃការអនុវត្តអនុកម្មវិធី ឬចង្កោមសកម្មភាពនីមួយៗ។ **រីឯគោលដៅសូចនាករលទ្ធផលចុងក្រោយ** គឺជាគោលដៅសមិទ្ធកម្មចុងក្រោយជា**បរិមាណ** ឬ/និងជា**គុណភាព** ដែលមានលក្ខណៈសាមញ្ញ ហើយគោលដៅមានភាពងាយស្រួលក្នុងការសម្រេចដែលអាចបង្ហាញអំពីវឌ្ឍភាពរបស់កម្មវិធី។ ក្នុងការកំណត់គោលដៅសូចនាករ, កត្តាចាំបាច់និងសំខាន់បំផុត គឺត្រូវដឹងអំពីស្ថានភាពបច្ចុប្បន្នរបស់សូចនាករទាំងនោះ ទើបអាចទៅកំណត់គោលដៅដែលចង់បាន ដើម្បីឱ្យឆ្លើយតបបានទៅនឹងគោលបំណងគោលនយោបាយដែលបានកំណត់ ហើយការកំណត់គោលដៅនេះចាំបាច់ត្រូវតែមានភាពសមស្រប និងប្រាកដនិយមដែលអាចអនុវត្តបាន។ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ(សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) **ត្រូវរៀបចំខ្លឹមសារនៃផ្នែកទី ៤ នេះ ទៅតាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។** *ក្នុងការអនុវត្តថវិកាសមិទ្ធកម្ម ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងផ្តោតការយកចិត្តទុកដាក់ជាបណ្តើរៗលើ **សមិទ្ធកម្ម** ដែលតម្រូវឱ្យក្រសួង-ស្ថាប័ន ត្រូវផ្តោតការយកចិត្តទុកដាក់កែលម្អសូចនាករឱ្យបានកាន់តែល្អប្រសើរ និងមានមូលដ្ឋានទិន្នន័យច្បាស់លាស់។*

- **ផ្នែកទី៥៖ ការកំណត់ធនធានថវិកា**

ក្រសួង-ស្ថាប័ននីមួយៗ ត្រូវគ្រោងទាំងធនធានថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ សម្រាប់អនុវត្តកម្មវិធី សម្រាប់រយៈពេលបីឆ្នាំរំកិល (២០២៣-២០២៥)។

ក-ការគ្រោងចំណូល

ការគ្រោងចំណូល គឺត្រូវគ្រោងសម្រាប់រយៈពេល ៣ ឆ្នាំ ២០២៣-២០២៥ ដោយរួមទាំងចំណូលថវិការដ្ឋ ដែលស្ថិតក្រោមការគ្រប់គ្រង និងប្រមូលផ្ទាល់ដោយក្រសួង-ស្ថាប័ន និងចំណូលដែលបានមកពីហិរញ្ញប្បទានសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងប្រភពផ្សេងៗទៀត។ ក្នុងការគ្រោងចំណូល ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវផ្តោតការយកចិត្តទុកដាក់លើចំណុចសំខាន់ៗ ដូចខាងក្រោម៖

- គោលដៅសូចនាករចំណូលនៃក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលបានដាក់ចេញនៅក្នុងសារាចរណែនាំនេះ
- ការវាយតម្លៃការអនុវត្តការប្រមូលចំណូលក្នុងឆ្នាំកន្លងទៅ និងការប៉ាន់ស្មានការអនុវត្តប្រមូលចំណូលក្នុងឆ្នាំកំពុងអនុវត្ត
- ការដាក់ចេញវិធានការដាក់ស្តែងបន្ថែមទៀតតាមក្រសួង-ស្ថាប័ននីមួយៗ ដើម្បីបង្កើនការប្រមូលចំណូល ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។

ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំផ្នែកនេះទៅតាម **តារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។** នៅក្នុងផ្នែកនេះ ចំពោះក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ដែលមិនមានប្រភពចំណូល គឺពុំតម្រូវឱ្យរៀបចំឡើយ។

ទន្ទឹមនេះ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានប្រភពចំណូល គឺត្រូវរៀបចំដាក់ចេញវិធានការដាក់ស្តែងបន្ថែមទៀតតាមក្រសួង-ស្ថាប័ននីមួយៗ សម្រាប់ពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។ *ផ្ទុយទៅវិញ ការគ្រោងចំណូលមិនអស់សក្តានុពលដែលមាន គឺជាកម្មវត្ថុនៃការរឹតត្បិតចំណាយនៅក្នុងដំណាក់កាលចរចាកញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់ក្រសួង-ស្ថាប័ន ដែលមានភារកិច្ចប្រមូលចំណូល។*

ខ-ការគ្រោងចំណាយថវិកា

ការគ្រោងតម្រូវការចំណាយ គឺជាការគណនាចំណាយសម្រាប់រយៈពេល ៣ ឆ្នាំ ២០២៣-២០២៥ ទៅតាមកម្មវិធីនីមួយៗ និងទៅតាមប្រភេទចំណាយ និងប្រភពធនធាន រួមទាំងថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍។ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវរៀបចំខ្លឹមសារនៃផ្នែកទី ៥ នេះ **តាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

ក្នុងការគណនាអំពីតម្រូវការថវិកា ដើម្បីអនុវត្តកម្មវិធីនីមួយៗ ត្រូវផ្តោតការយកចិត្តទុកដាក់លើចំណុចសំខាន់ៗ ដូចខាងក្រោម៖

ទី១-ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈដែលរាជរដ្ឋាភិបាលបានដាក់ចេញ តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលរួមមានគោលដៅសូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ដូចជា កំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ អត្រាអតិផរណាប្រចាំឆ្នាំ និងគោលដៅសូចនាករចំណាយ

ព្រមជាមួយនឹងគោលនយោបាយអាទិភាពចំណាយ ទាំងផ្នែកចំណាយចរន្ត និងចំណាយមូលធន (ឬហៅថាចំណាយវិនិយោគ)។ ក្នុងន័យនេះ *ពិតានចំណាយគោលនៃចំណាយចរន្តរបស់ក្រសួង-ស្ថាប័ន ត្រូវបានផ្តល់ជាកញ្ចប់ថវិកាសម្រាប់រយៈពេល ៣ ឆ្នាំ (២០២៣-២០២៥) ទាំងផ្នែកចំណាយបន្ទុកបុគ្គលិក (ដោយមិនគិតបញ្ចូលនូវផ្ញើរនៅពីសេវាសាធារណៈ) និងចំណាយមិនមែនបន្ទុកបុគ្គលិកទៅតាមគោលការណ៍ដែលលម្អិតនៅក្នុងផ្នែក ២.៣*។ ទន្ទឹមនេះ ក្រសួងចំនួន ៩ ដែលទទួលបានកញ្ចប់ចំណាយវិនិយោគជាប្រចាំ ក៏ទទួលបានកញ្ចប់ពិតានចំណាយគោលនៃចំណាយមូលធនសម្រាប់គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាជាតិ និងហិរញ្ញប្បទានសហប្រតិបត្តិការដោយដៃគូអភិវឌ្ឍន៍ផងដែរ។

ទី២-ការវាយតម្លៃអំពីសមត្ថភាពក្នុងការអនុវត្តចំណាយក្នុងរយៈពេលកន្លងមក និងការប៉ាន់ស្មានសមត្ថភាពអនុវត្តចំណាយក្នុងឆ្នាំ ២០២២ ដែលក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត គ្រឹះស្ថានសាធារណៈរដ្ឋបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ បាននិងកំពុងអនុវត្ត,

ទី៣-ការកំណត់តម្រូវការថវិកាតាមឆ្នាំនីមួយៗ ត្រូវគណនាចំណាយប្រកបដោយសុក្រឹតភាពទៅតាមតម្រូវការជាក់ស្តែងនៃកម្មវិធីនីមួយៗ ដោយត្រូវគិតគូរឈរលើទិដ្ឋភាពបី៖

- ផែនការសកម្មភាព ឬសកម្មភាពការងារដែលមានស្រាប់ដែលត្រូវបន្តអនុវត្ត ដើម្បីសម្រេចគោលនយោបាយរបស់ក្រសួង-ស្ថាប័នរៀងខ្លួន,
- ផែនការសកម្មភាព ឬសកម្មភាពការងារដែលមានលក្ខណៈបញ្ចប់ត្រឹមមួយឆ្នាំ, និង
- ផែនការសកម្មភាព ឬសកម្មភាពការងារថ្មី ដើម្បីសម្រេចគោលនយោបាយរបស់ក្រសួង-ស្ថាប័នរៀងខ្លួន។

ដូច្នេះ ផ្អែកលើគោលការណ៍ទាំងបីខាងលើនេះ គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទទាំងអស់ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវគ្រោងតម្រូវការចំណាយសម្រាប់ឆ្នាំ ២០២៣-២០២៥ តាមគោលការណ៍នៃការកំណត់កញ្ចប់ថវិកា ដូចខាងក្រោម៖

- **ចំណាយបន្ទុកបុគ្គលិក** (ជំពូក ៦៤)៖ ទោះបីសេដ្ឋកិច្ចជាតិនៅបន្តរងផលប៉ះពាល់អវិជ្ជមានពីវិបត្តិកូវីដ-១៩ និងផលប៉ះពាល់ពីសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន រាជរដ្ឋាភិបាលនៅតែខិតខំគិតគូរលើការដំឡើងបៀវត្សជូនមន្ត្រីរាជការឱ្យខិតទៅកៀកនឹងគោលដៅ ដែលបានកំណត់កាលពីដើមអាណត្តិនៃនីតិកាលទី ៦ នៃរដ្ឋសភា។ ដូចនេះ សម្រាប់ឆ្នាំ ២០២៣ ត្រូវគ្រោងតាមគោលការណ៍ ដូចខាងក្រោម៖

(១)-ផ្អែកលើមូលដ្ឋាននៃចំនួនក្របខ័ណ្ឌមន្ត្រីរាជការឆ្នាំ ២០២២ ចំនួនក្របខ័ណ្ឌថ្មីត្រូវបានអនុញ្ញាតឱ្យជ្រើសរើសសម្រាប់បំពេញជំនួសតែចំនួនមន្ត្រីដែលចូលនិវត្តន៍នៅក្នុងឆ្នាំ ២០២២។ ចំពោះ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានអនុញ្ញាតឱ្យជ្រើសរើសក្របខ័ណ្ឌគ្រូឡើងវិញ ចំនួន ៣ ០០០ កន្លែង បន្ទាប់ពីអាក់ខានចំនួន ២ ឆ្នាំ។ ដោយឡែក ក្រសួងសុខាភិបាលត្រូវផ្អាកការជ្រើសរើសក្របខ័ណ្ឌថ្មីបន្ថែមទៀតសិន ដោយសារ ក្រសួងសុខាភិបាលត្រូវបានរាជរដ្ឋាភិបាលអនុញ្ញាតឱ្យជ្រើសរើសក្របខ័ណ្ឌច្រើនរួចហើយ នៅក្នុងឆ្នាំ ២០២១ និងឆ្នាំ ២០២២ នេះ។ ទន្ទឹមនេះ មន្ត្រីដែលព្យួរការងារ និងមន្ត្រីដែលចូលបម្រើការងារវិញ ក៏ជាកម្មវត្ថុនៃការគ្រប់គ្រងឱ្យបានត្រឹមត្រូវ និងហ្មត់ចត់ផងដែរ។

(២)-គ្រោងដំឡើងប្រាក់បំណាច់មុខងារជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដោយផ្តល់បន្ថែមជូនចំនួន ១២៧ ៥០០ រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារក្នុងកម្រិតក្រោម ៧៦០ ០០០ រៀល ចុះ, ផ្តល់បន្ថែមជូន ១២០ ០០០ រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារក្នុងកម្រិតចាប់ត្រឹមពី ៧៦០ ០០០ រៀល ដល់ ៩៩០ ០០០ រៀល, និងផ្តល់បន្ថែមជូន ១០០ ០០០ រៀល សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារក្នុងកម្រិតចាប់ត្រឹមពី ១ ០៣០ ០០ រៀល ឡើង ដោយគិតចាប់ពីខែ មករា ដល់ខែ ធ្នូ។ ចំពោះសន្ទស្សន៍បៀវត្សមូលដ្ឋានត្រូវរក្សាស្មើនឹងកម្រិតឆ្នាំ ២០២២ (តម្លៃសន្ទស្សន៍ក្នុង ១ ឯកតា ស្មើនឹង ២ ៥០០រៀល)។ ដូចនេះ សម្រាប់ឆ្នាំ ២០២៤ និង ២០២៥ ត្រូវគ្រោងដោយផ្អែកលើមូលដ្ឋាននៃកម្រិតក្របខ័ណ្ឌ និងកម្រិតបៀវត្សឆ្នាំ ២០២៣ និងឆ្នាំ ២០២៤ រៀងគ្នា,

(៣)-គ្រោងប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីចូលឆ្នាំថ្មីប្រពៃណីជាតិចំនួន **៥ ម៉ឺនរៀល** ក្នុងម្នាក់ និងក្នុងឱកាសបុណ្យភ្ជុំបិណ្ឌចំនួន **៥ ម៉ឺនរៀល ក្នុងម្នាក់** ជូនដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រមទាំងនិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន និង

(៤)-គ្រោង**ចំនួនមន្ត្រីជាប់កិច្ចសន្យាមិនឱ្យលើសពីចំនួន** ដែលក្រសួងមុខងារសាធារណៈផ្តល់ជូនក្នុងឆ្នាំ ២០២២ ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ចំពោះប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់មន្ត្រីជាប់កិច្ចសន្យាត្រូវគ្រោង**ដំឡើងពី ៦៧០ ០០០ រៀល ទៅដល់ ៧១០ ០០០ រៀល** ដោយគិតចាប់ពីខែមករា ដល់ខែធ្នូ។

ជាមួយគ្នានេះ សម្រាប់ឆ្នាំ ២០២៣ រាជរដ្ឋាភិបាលបានគិតគូរផងដែរលើការដំឡើងប្រាក់សោធនជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន និងជាពិសេសគិតគូរកាត់បន្ថយគម្លាតប្រាក់សោធនរវាងអ្នកចូលនិវត្តចាស់ និងថ្មីឱ្យបានឆាប់ ដោយបានត្រៀមបម្រុងកញ្ចប់ថវិកាចំនួន **១៦០ ប៊ីលានរៀល** នៅក្នុងចំណាយមិនទាន់បែងចែករបស់រាជរដ្ឋាភិបាល។ គោលការណ៍លម្អិតសម្រាប់អនុវត្តនឹងត្រូវកំណត់ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល។

- **ចំណាយក្រៅបន្ទុកបុគ្គលិក** (ជំពូក ៦០ ការទិញ, ជំពូក ៦១ សេវាកម្ម, ជំពូក ៦២ អត្ថប្រយោជន៍សង្គម, ជំពូក ៦៥ ឧបត្ថម្ភធន) ជាសរុបសម្រាប់ឆ្នាំ ២០២៣ ត្រូវគ្រោងតាមគោលការណ៍ ដូចខាងក្រោម៖
  - **ក្រសួង-ស្ថាប័ននៅរដ្ឋបាលកណ្តាល៖** ត្រូវគ្រោងថវិកាទៅតាមទំហំពិតានចំណាយគោលឆ្នាំ ២០២៣-២០២៥ ប៉ុន្តែ កញ្ចប់ថវិកាតាមពិតានចំណាយគោលនេះនឹងមិនទទួលបានជាស្វ័យប្រវត្តិនោះទេ គឺនៅជាកម្មវត្ថុនៃការពិនិត្យ និងពិភាក្សា ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការវិភាជន៍ថវិកា និងប្រតិបត្តិការចំណាយ។ ទន្ទឹមនេះ រាល់ការគ្រោងចំណាយទាំងអស់ត្រូវភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធ រួមមាន៖ ការសិក្សា វិភាគ វាយតម្លៃ និងអំណះអំណាងត្រឹមត្រូវ ជាក់លាក់ និងច្បាស់លាស់ ទើបអាចដាក់ជាកម្មវត្ថុនៃការពិចារណា និងពិភាក្សាចរចា នៅពេលរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំបាន។
  - **មន្ទីរជំនាញរាជធានី-ខេត្តនៃក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត** (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល)៖ ផ្អែកលើទំហំពិតានចំណាយគោលរួមដែលផ្តល់ជូនដល់មន្ទីរជំនាញរាជធានី-ខេត្ត ត្រូវគ្រោងយ៉ាងច្រើនបំផុតស្មើនឹងកម្រិតថវិកាអតិបរមានៃទំហំពិតានចំណាយគោល។ ប៉ុន្តែត្រូវកត់សម្គាល់ថា កញ្ចប់ថវិកាដែលគ្រោងផ្តល់នេះ មិនទទួលបានជាស្វ័យ-

ប្រវត្តិទេ គឺតម្រូវឱ្យមន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលរាជធានី-ខេត្តនីមួយៗ ដែលទទួលបាននូវការប្រគល់មុខងារពីក្រសួងសុខាភិបាល ត្រូវផ្តល់ឯកសារពាក់ព័ន្ធដែលមានការសិក្សា វិភាគ វាយតម្លៃ និងអំណះអំណាងត្រឹមត្រូវ ជាក់លាក់ និងច្បាស់លាស់ ព្រោះការគ្រោងចំណាយត្រូវកាត់ចេញមុខចំណាយលើសកម្មភាពការងារដែលត្រូវបានបញ្ចប់ ជាពិសេសចំណាយមិនប្រចាំ ដើម្បីសន្សំសំចៃសម្រាប់បំពេញតម្រូវការសកម្មភាពថ្មីដែលចាំបាច់ តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

- ដោយឡែក សម្រាប់មុខងារមានភ្ជាប់លក្ខខណ្ឌក្នុងវិស័យអប់រំ ការគ្រោងកញ្ចប់ថវិកាត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងស្តីពីលក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុ សម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុងស្រុកទាំង ១៤ ក្នុងខេត្តបាត់ដំបង សម្រាប់អនុវត្តមុខងារគ្រប់គ្រង ការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ។
- **គ្រឹះស្ថានសាធារណៈរដ្ឋបាលនៃក្រសួង-ស្ថាប័ននីមួយៗ** ត្រូវបានគ្រោងផ្តល់កញ្ចប់ថវិកាឧបត្ថម្ភធនសម្រាប់រយៈពេល ៣ ឆ្នាំ (២០២៣-២០២៥) **ប៉ុន្តែកញ្ចប់ឧបត្ថម្ភធនដែលគ្រោងផ្តល់នេះមិនទទួលបានជាស្វ័យប្រវត្តិទេ** គឺតម្រូវឱ្យគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ ត្រូវផ្តល់ការពន្យល់ និងអំណះអំណាងត្រឹមត្រូវជាក់លាក់ និងច្បាស់លាស់នូវស្ថានភាពចំណូលផ្ទៃក្នុងរបស់គ្រឹះស្ថាន និងម្យ៉ាងទៀតក៏ត្រូវកាត់ចេញនូវទំហំចំណាយសម្រាប់សកម្មភាពដែលត្រូវបានបញ្ចប់ ជាពិសេសចំណាយមិនប្រចាំ ដើម្បីសន្សំសំចៃ ក៏ដូចជាសម្រាប់បំពេញតម្រូវការសកម្មភាពថ្មីដែលចាំបាច់។

- **ចំណាយមូលធនសម្រាប់គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានថវិកាជាតិ** (ជំពូក២១)៖ ត្រូវបានផ្តល់ជាពិតានចំណាយគោលសម្រាប់ក្រសួង-ស្ថាប័នចំនួន ៩ រួមមាន៖ ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងមហាផ្ទៃ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងសុខាភិបាល, និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។ ពាក់ព័ន្ធនឹងវិស័យផ្លូវថ្នល់, ធារាសាស្ត្រ , អប់រំ និងវិស័យសុខាភិបាល, ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល ត្រូវរៀបចំផែនការវិនិយោគសាធារណៈ ៣ ឆ្នាំរំកិល ជាបញ្ជីគម្រោងសម្រាប់ឆ្នាំ ២០២៣-២០២៥ ដើម្បីជាមូលដ្ឋានសម្រាប់ធ្វើសមាហរណកម្មគម្រោងចំណាយវិនិយោគ ជាមួយនឹងគម្រោងចំណាយចរន្តនៅកម្រិតកម្មវិធី និងអនុកម្មវិធី និងដោយភ្ជាប់ជាមួយនូវបញ្ជីគម្រោងដែលបានរៀបចំ។ ចំពោះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងមហាផ្ទៃ និង ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នឹងត្រូវបន្តអនុវត្តរៀបចំផែនការវិនិយោគសាធារណៈ ៣ ឆ្នាំ រំកិល ដើម្បីត្រៀមលក្ខណៈចាប់ផ្តើមធ្វើសមាហរណកម្មគម្រោងចំណាយវិនិយោគ តាមការចាំបាច់នៅឆ្នាំខាងមុខជាមួយនឹងគម្រោងចំណាយចរន្ត នៅកម្រិតកម្មវិធី និងអនុកម្មវិធី។ ទោះយ៉ាងនេះក្តី ក្រសួងទាំង ៩ ខាងលើនេះនឹងមិនទទួលបានកញ្ចប់ចំណាយវិនិយោគជាស្វ័យប្រវត្តិទេ, ការធ្វើអាទិភាវូបនីយកម្មគម្រោង និងផ្តល់ថវិកា គឺជាកម្មវត្ថុនៃការពិនិត្យពិភាក្សាតាមយន្តការគណៈកម្មការ ឬក្រុមការងារអន្តរក្រសួង។ ចំពោះក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដែលមានតម្រូវការចំណាយវិនិយោគត្រូវសិក្សាឱ្យបានច្បាស់លាស់ និងរៀបចំលើកសំណើ

គម្រោងក្នុងកម្រិតទំហំថវិកាសមស្រប ដើម្បីឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរៀបចំធ្វើអាទិភាវូបនីយកម្មគម្រោង ហើយគោរពស្នើសុំប្រមុខរាជរដ្ឋាភិបាល ពិនិត្យ និងសម្រេចតាមលទ្ធភាពថវិកា និងវិធានការផ្នែកចំណាយ ដែលបានកំណត់នៅផ្នែកខាងលើនៃសារាចរណែនាំនេះ។

- **ចំណាយមូលធន/វិនិយោគដោយហិរញ្ញប្បទានសហប្រតិបត្តិការដោយដៃគូអភិវឌ្ឍន៍៖** ត្រូវបានផ្តល់ជាពិតានចំណាយគោលសម្រាប់ក្រសួង-ស្ថាប័នចំនួន ៩ ដូចចំណាយមូលធនថ្នាក់ជាតិខាងលើដែរ។ ចំពោះក្រសួង-ស្ថាប័នដទៃទៀត ដែលបាននិងកំពុងទទួលបានហិរញ្ញប្បទានសហប្រតិបត្តិការ ឬគ្រោងនឹងទទួលបានហិរញ្ញប្បទាន ស្របតាមកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល(២០២៣-២០២៥) ត្រូវគ្រោងឱ្យបានត្រឹមត្រូវទៅតាមកិច្ចព្រមព្រៀង ឬអនុស្សារណៈនៃការយោគយល់គ្នា ឬការសន្យាតាមរយៈយន្តការផ្សេងៗ។

- **ផ្នែកទី៦៖ សេចក្តីសន្និដ្ឋាន**

ផ្នែកចុងក្រោយ គឺជាការសន្និដ្ឋានទៅលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៣-២០២៥ និងការលើកទិសដៅ និងវិធានការ ដើម្បីសម្រេចគោលដៅដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៣-២០២៥។

## ៤-សេចក្តីសន្និដ្ឋាន

ក្នុងក្របខ័ណ្ឌនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា គឺជាវិធានការសំខាន់សម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃការរៀបចំថវិកា និងការបែងចែកធនធានថវិកា។ ក្នុងន័យនេះ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) ត្រូវត្រួតពិនិត្យឡើងវិញ និងវាយតម្លៃការអនុវត្តកន្លងមក ហើយរៀបចំកែសម្រួលទៅតាមការណែនាំនៃសារាចរនេះ។ ជារួម *គុណភាពនៃផែនការយុទ្ធសាស្ត្រ គឺជាកម្មវត្ថុនៃការរឹតត្បិត ឬលើកទឹកចិត្តចំណាយនៅក្នុងដំណាក់កាលចរចាកញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់គ្រប់ក្រសួង-ស្ថាប័ន។*

សម្រាប់ឆ្នាំ ២០២៣ និងបណ្តាឆ្នាំខាងមុខ, ក្រសួង-ស្ថាប័នត្រូវយកចិត្តទុកដាក់កែលម្អផែនការយុទ្ធសាស្ត្រថវិកាឱ្យស្របទៅតាមអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល និងត្រូវគ្រោងចំណាយស្របទៅតាមពិតានចំណាយគោលរយៈពេល ៣ ឆ្នាំ និងធនធានដទៃទៀតដែលរំពឹងថានឹងទទួលបានពីដៃគូអភិវឌ្ឍន៍ ឬប្រភពដទៃផ្សេងទៀត ប្រកបដោយភាពជាក់ស្តែងនិយម។

*គ្រប់ក្រសួង-ស្ថាប័នទាំងអស់ ត្រូវបញ្ជូនផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ ២០២៣-២០២៥ ដែលមានវិសាលភាពគ្របដណ្តប់ទាំងផែនការយុទ្ធសាស្ត្រថវិការបស់មន្ទីរជំនាញរាជធានី-ខេត្ត របស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (សម្រាប់មុខងារប្រគល់មានភ្ជាប់លក្ខខណ្ឌក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ) មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី១ ខែ កក្កដា ឆ្នាំ ២០២២* ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានពេលវេលាគ្រប់គ្រាន់សម្រាប់ពិនិត្យនិងបូកសរុប និងស្នើសុំការបំភ្លឺបន្ថែមតាមការចាំបាច់ពីក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត គ្រឹះស្ថានសាធារណៈរដ្ឋបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ។ ដើម្បីសម្រួលដល់ដំណើរការពិនិត្យ និងបូកសរុបផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង-ស្ថាប័ននីមួយៗ *គ្រឹះស្ថានសាធារណៈរដ្ឋបាល មន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវបញ្ជូនផែនការយុទ្ធសាស្ត្រ*

*ថវិកាមួយច្បាប់ទៅក្រសួង-ស្ថាប័នសាមី និងមួយច្បាប់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) តាមពេលវេលាដែលបានកំណត់ខាងលើ។* ប្រសិនបើក្រសួង-ស្ថាប័នមិនបានផ្តល់ផែនការយុទ្ធសាស្ត្រថវិកាតាមពេលវេលាកំណត់ខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យស្នើការរិភាជកញ្ចប់ថវិកាប្រចាំឆ្នាំដោយផ្អែកលើមូលដ្ឋាននៃផែនការយុទ្ធសាស្ត្រថវិកាឆ្នាំចាស់ និងការអនុវត្តថវិកានៃឆ្នាំកន្លងទៅ។

ទទួលបានសារាចរណែនាំនេះ ក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល មន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ និងឱ្យបានទាន់ឱសានវាទ។ ក្នុងករណីក្រសួង-ស្ថាប័ន គ្រឹះស្ថានសាធារណៈរដ្ឋបាល មន្ទីរជំនាញរាជធានី-ខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធមានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេសរៀបចំ ត្រូវទាក់ទងមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០២៣-២០២៥ **ឱ្យបានទាន់ពេលវេលាតាមកាលកំណត់ និងផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០២២។**

ថ្ងៃ ពុធ ៩ កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែមិថុនា ឆ្នាំ ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល៖</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
"ដើម្បីជូនជ្រាប"
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-រាជកិច្ច "ដើម្បីចុះផ្សាយ"
-គ្រប់ក្រសួង-ស្ថាប័ន
-គ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល
-គ្រប់អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត
-គ្រប់មន្ទីរជំនាញរាជធានី-ខេត្ត
-រដ្ឋបាលក្រុង-ស្រុកទាំង ១៤ នៃខេត្តបាត់ដំបង
"ដើម្បីមុខការ"
-ឯកសារ-កាលប្បវត្តិ

លេខ ១៩០ អយក.ចល
បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
បញ្ជូនមក:-គ្រប់អង្គភាពនិងគ្រឹះស្ថានសិក្សាក្រោមឱវាទក្រសួង
-គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
" ដើម្បីមុខការនិងអនុវត្ត"
ថ្ងៃសុក្រ ១១កើត ខែ ជេស្ឋ ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០២២
**តប.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
**អគ្គនាយក**

**ឆេង_តិយ៉ារិទ្ធ**

# គម្រោងថវិកាឆ្នាំ ២០២៣-២០២៥

# តាមក្រសួង-ស្ថាប័ន

ឯកតា:លានរៀល

| បរិយាយ | គម្រោងថវិកាឆ្នាំ ២០២៣ | គម្រោងថវិកាឆ្នាំ ២០២៤ | គម្រោងថវិកាឆ្នាំ ២០២៥ |
|---|---|---|---|
| សរុបរួម | 19.524.863 | 20.213.040 | 20.732.980 |
| **០១. ព្រះបរមរាជវាំង** | **77.090** | **79.533** | **82.086** |
| សរុបចំណាយចរន្ត | **77.090** | **79.533** | **82.086** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 36.697 | 38.532 | 40.459 |
| មិនមែនបន្ទុកបុគ្គលិក | 40.392 | 41.000 | 41.627 |
| **០២. រដ្ឋសភា** | **148.741** | **154.962** | **161.471** |
| សរុបចំណាយចរន្ត | **148.741** | **154.962** | **161.471** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 101.528 | 106.604 | 111.935 |
| មិនមែនបន្ទុកបុគ្គលិក | 47.213 | 48.357 | 49.536 |
| **០៣. ព្រឹទ្ធសភា** | **71.199** | **74.193** | **77.327** |
| សរុបចំណាយចរន្ត | **71.199** | **74.193** | **77.327** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 50.555 | 53.083 | 55.737 |
| មិនមែនបន្ទុកបុគ្គលិក | 20.644 | 21.110 | 21.591 |
| **០៤. ក្រុមប្រឹក្សាធម្មនុញ្ញ** | **12.883** | **13.484** | **14.115** |
| សរុបចំណាយចរន្ត | **12.883** | **13.484** | **14.115** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 10.962 | 11.510 | 12.085 |
| មិនមែនបន្ទុកបុគ្គលិក | 1.921 | 1.974 | 2.030 |
| **០៥.១. ទីស្តីការគណៈរដ្ឋមន្ត្រី** | **367.191** | **372.133** | **377.286** |
| សរុបចំណាយចរន្ត | **367.191** | **372.133** | **377.286** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 61.701 | 64.786 | 68.026 |
| មិនមែនបន្ទុកបុគ្គលិក | 305.490 | 307.347 | 309.260 |
| ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 10.799 | 11.122 | 11.456 |
| **០៥.៣. រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល** | **38.337** | **39.537** | **40.790** |
| សរុបចំណាយចរន្ត | **38.337** | **39.537** | **40.790** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 18.231 | 19.142 | 20.099 |
| មិនមែនបន្ទុកបុគ្គលិក | 20.106 | 20.394 | 20.691 |
| **០៥.៤. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** | **8.434** | **8.710** | **8.995** |
| សរុបចំណាយចរន្ត | **8.434** | **8.710** | **8.995** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 1.175 | 1.234 | 1.295 |
| មិនមែនបន្ទុកបុគ្គលិក | 7.259 | 7.476 | 7.700 |
| **០៦. ក្រសួងការពារជាតិ** | **2.728.798** | **2.857.386** | **2.992.199** |
| សរុបចំណាយចរន្ត | **2.728.798** | **2.857.386** | **2.992.199** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 2.367.833 | 2.486.224 | 2.610.535 |
| មិនមែនបន្ទុកបុគ្គលិក | 360.965 | 371.162 | 381.664 |

# គម្រោងថវិកាឆ្នាំ ២០២៣-២០២៥
# តាមក្រសួង-ស្ថាប័ន

ឯកតា:លានរៀល

| បរិយាយ | គម្រោងថវិកាឆ្នាំ ២០២៣ | គម្រោងថវិកាឆ្នាំ ២០២៤ | គម្រោងថវិកាឆ្នាំ ២០២៥ |
|---|---|---|---|
| **០៧.១. ក្រសួងមហាផ្ទៃ-សន្តិសុខសាធារណៈ** | **1.765.284** | **1.844.828** | **1.928.164** |
| **សរុបចំណាយចរន្ត** | **1.740.284** | **1.819.828** | **1.903.164** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 1.405.438 | 1.475.710 | 1.549.496 |
| មិនមែនបន្ទុកបុគ្គលិក | 334.845 | 344.118 | 353.668 |
| **សរុបចំណាយមូលធន** | **25.000** | **25.000** | **25.000** |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 25.000 | 25.000 | 25.000 |
| - គម្រោងវិនិយោគ | 25.000 | 25.000 | 25.000 |
| **០៧.២. ក្រសួងមហាផ្ទៃ-រដ្ឋបាលទូទៅ** | **351.411** | **372.453** | **384.923** |
| **សរុបចំណាយចរន្ត** | **315.060** | **328.494** | **342.545** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 214.394 | 225.113 | 236.369 |
| មិនមែនបន្ទុកបុគ្គលិក | 100.667 | 103.381 | 106.176 |
| **សរុបចំណាយមូលធន** | **36.351** | **43.959** | **42.378** |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 5.000 | 5.000 | 5.000 |
| - គម្រោងវិនិយោគ | 5.000 | 5.000 | 5.000 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 31.351 | 38.959 | 37.378 |
| **០៨. ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច** | **40.056** | **41.727** | **43.472** |
| **១.ក្រសួង** | **20.864** | **21.783** | **22.745** |
| **សរុបចំណាយចរន្ត** | **20.864** | **21.783** | **22.745** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 14.738 | 15.475 | 16.248 |
| មិនមែនបន្ទុកបុគ្គលិក | 6.126 | 6.309 | 6.496 |
| **៩.មន្ទីរជំនាញ** | **19.192** | **19.944** | **20.727** |
| **សរុបចំណាយចរន្ត** | **19.192** | **19.944** | **20.727** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 8.833 | 9.275 | 9.738 |
| មិនមែនបន្ទុកបុគ្គលិក | 10.359 | 10.669 | 10.989 |
| **០៩. ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** | **155.663** | **161.212** | **166.984** |
| **សរុបចំណាយចរន្ត** | **155.663** | **161.212** | **166.984** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 55.875 | 58.668 | 61.602 |
| មិនមែនបន្ទុកបុគ្គលិក | 99.789 | 102.544 | 105.382 |
| **១០. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | **438.037** | **449.033** | **460.502** |
| **១.ក្រសួង** | **410.031** | **419.931** | **430.259** |
| **សរុបចំណាយចរន្ត** | **410.031** | **419.931** | **430.259** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 130.455 | 136.978 | 143.827 |
| មិនមែនបន្ទុកបុគ្គលិក | 279.576 | 282.953 | 286.432 |
| ក្នុងនោះ:គ្រឹះស្ថានសាធារណៈរដ្ឋបាល | 5.102 | 5.255 | 5.412 |

# គម្រោងថវិកាឆ្នាំ ២០២៣-២០២៥
## តាមក្រសួង-ស្ថាប័ន

ឯកតា:លានរៀល

| បរិយាយ | គម្រោងថវិកាឆ្នាំ ២០២៣ | គម្រោងថវិកាឆ្នាំ ២០២៤ | គម្រោងថវិកាឆ្នាំ ២០២៥ |
|---|---|---|---|
| ៩.មន្ទីរជំនាញ | **28.006** | **29.102** | **30.244** |
| សរុបចំណាយចរន្ត | **28.006** | **29.102** | **30.244** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 12.839 | 13.481 | 14.155 |
| មិនមែនបន្ទុកបុគ្គលិក | 15.167 | 15.621 | 16.089 |
| **១១. ក្រសួងព័ត៌មាន** | **77.481** | **80.706** | **84.074** |
| ១.ក្រសួង | **50.967** | **53.110** | **55.349** |
| សរុបចំណាយចរន្ត | **50.967** | **53.110** | **55.349** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 31.818 | 33.408 | 35.079 |
| មិនមែនបន្ទុកបុគ្គលិក | 19.149 | 19.702 | 20.270 |
| ៩.មន្ទីរជំនាញ | **26.515** | **27.596** | **28.725** |
| សរុបចំណាយចរន្ត | **26.515** | **27.596** | **28.725** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 14.322 | 15.038 | 15.790 |
| មិនមែនបន្ទុកបុគ្គលិក | 12.193 | 12.558 | 12.935 |
| **១២. ក្រសួងសុខាភិបាល** | **1.515.927** | **1.401.097** | **1.586.544** |
| ១.ក្រសួង | **1.503.129** | **1.387.865** | **1.572.860** |
| សរុបចំណាយចរន្ត | **933.258** | **946.445** | **960.151** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 122.969 | 129.117 | 135.573 |
| មិនមែនបន្ទុកបុគ្គលិក | 810.289 | 817.328 | 824.578 |
| ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 57.672 | 59.402 | 61.184 |
| សរុបចំណាយមូលធន | **569.872** | **441.420** | **612.709** |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 40.000 | 40.000 | 40.000 |
| - គម្រោងវិនិយោគ | 40.000 | 40.000 | 40.000 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 529.872 | 401.420 | 572.709 |
| ៩.សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ | **12.798** | **13.232** | **13.684** |
| សរុបចំណាយចរន្ត | **12.798** | **13.232** | **13.684** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 4.424 | 4.646 | 4.878 |
| មិនមែនបន្ទុកបុគ្គលិក | 8.373 | 8.587 | 8.806 |
| **១៣. ក្រសួងរ៉ែ និងថាមពល** | **44.851** | **46.619** | **48.461** |
| ១.ក្រសួង | **25.081** | **26.094** | **27.150** |
| សរុបចំណាយចរន្ត | **25.081** | **26.094** | **27.150** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 13.561 | 14.239 | 14.951 |
| មិនមែនបន្ទុកបុគ្គលិក | 11.520 | 11.855 | 12.199 |

# គម្រោងថវិកាឆ្នាំ ២០២៣-២០២៥

## តាមក្រសួង-ស្ថាប័ន

ឯកតា:លានរៀល

| បរិយាយ | គម្រោងថវិកាឆ្នាំ ២០២៣ | គម្រោងថវិកាឆ្នាំ ២០២៤ | គម្រោងថវិកាឆ្នាំ ២០២៥ |
|---|---|---|---|
| ៩.មន្ទីរជំនាញ | **19.770** | **20.525** | **21.312** |
| សរុបចំណាយចរន្ត | **19.770** | **20.525** | **21.312** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 8.274 | 8.687 | 9.122 |
| មិនមែនបន្ទុកបុគ្គលិក | 11.496 | 11.838 | 12.190 |
| **១៤. ក្រសួងផែនការ** | **77.146** | **80.599** | **84.214** |
| ១.ក្រសួង | **35.168** | **36.748** | **38.401** |
| សរុបចំណាយចរន្ត | **35.168** | **36.748** | **38.401** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 26.459 | 27.782 | 29.171 |
| មិនមែនបន្ទុកបុគ្គលិក | 8.709 | 8.965 | 9.230 |
| ៩.មន្ទីរជំនាញ | **41.978** | **43.852** | **45.813** |
| សរុបចំណាយចរន្ត | **41.978** | **43.852** | **45.813** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 30.766 | 32.304 | 33.920 |
| មិនមែនបន្ទុកបុគ្គលិក | 11.212 | 11.547 | 11.893 |
| **១៥. ក្រសួងពាណិជ្ជកម្ម** | **93.018** | **96.582** | **100.298** |
| ១.ក្រសួង | **71.094** | **73.808** | **76.639** |
| សរុបចំណាយចរន្ត | **71.094** | **73.808** | **76.639** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 35.110 | 36.865 | 38.708 |
| មិនមែនបន្ទុកបុគ្គលិក | 35.984 | 36.943 | 37.931 |
| ៩.មន្ទីរជំនាញ | **21.924** | **22.773** | **23.658** |
| សរុបចំណាយចរន្ត | **21.924** | **22.773** | **23.658** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 9.617 | 10.098 | 10.603 |
| មិនមែនបន្ទុកបុគ្គលិក | 12.306 | 12.675 | 13.055 |
| **១៦. ក្រសួងអប់រំ យុវជន និងកីឡា** | **3.398.442** | **3.557.064** | **3.649.058** |
| ១.ក្រសួង | **490.469** | **513.955** | **464.198** |
| សរុបចំណាយចរន្ត | **355.483** | **365.503** | **375.944** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 120.997 | 127.047 | 133.399 |
| មិនមែនបន្ទុកបុគ្គលិក | 234.486 | 238.456 | 242.545 |
| ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 8.684 | 8.945 | 9.213 |
| សរុបចំណាយមូលធន | **134.987** | **148.453** | **88.254** |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 50.000 | 50.000 | 50.000 |
| - គម្រោងវិនិយោគ | 50.000 | 50.000 | 50.000 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 84.987 | 98.453 | 38.254 |

# គម្រោងថវិកាឆ្នាំ ២០២៣-២០២៥

## តាមក្រសួង-ស្ថាប័ន

ឯកតា:លានរៀល

| បរិយាយ | គម្រោងថវិកាឆ្នាំ ២០២៣ | គម្រោងថវិកាឆ្នាំ ២០២៤ | គម្រោងថវិកាឆ្នាំ ២០២៥ |
|---|---|---|---|
| ១.១. ផ្នែកអប់រំ | **412.293** | **434.982** | **384.403** |
| សរុបចំណាយចរន្ត | **277.306** | **286.529** | **296.148** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 119.825 | 125.816 | 132.107 |
| មិនមែនបន្ទុកបុគ្គលិក | 157.481 | 160.713 | 164.041 |
| ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 8.684 | 8.945 | 9.213 |
| សរុបចំណាយមូលធន | **134.987** | **148.453** | **88.254** |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 50.000 | 50.000 | 50.000 |
| - គម្រោងវិនិយោគ | 50.000 | 50.000 | 50.000 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 84.987 | 98.453 | 38.254 |
| ១.២. ផ្នែកឧត្តមសិក្សា | **27.652** | **28.113** | **28.589** |
| សរុបចំណាយចរន្ត | **27.652** | **28.113** | **28.589** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 977 | 1.026 | 1.077 |
| មិនមែនបន្ទុកបុគ្គលិក | 26.675 | 27.087 | 27.511 |
| ១.៣. ផ្នែកយុវជន និងកីឡា | **50.524** | **50.861** | **51.207** |
| សរុបចំណាយចរន្ត | **50.524** | **50.861** | **51.207** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 195 | 205 | 215 |
| មិនមែនបន្ទុកបុគ្គលិក | 50.329 | 50.656 | 50.992 |
| ៩.មន្ទីរជំនាញ | **2.907.972** | **3.043.109** | **3.184.859** |
| សរុបចំណាយចរន្ត | **2.907.972** | **3.043.109** | **3.184.859** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 2.559.445 | 2.687.418 | 2.821.788 |
| មិនមែនបន្ទុកបុគ្គលិក | 348.527 | 355.691 | 363.071 |
| **១៧. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | **418.204** | **458.645** | **327.398** |
| ១.ក្រសួង | **316.110** | **352.516** | **217.054** |
| សរុបចំណាយចរន្ត | **152.038** | **157.983** | **164.180** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 73.268 | 76.931 | 80.778 |
| មិនមែនបន្ទុកបុគ្គលិក | 78.770 | 81.052 | 83.402 |
| ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 19.804 | 20.399 | 21.010 |
| សរុបចំណាយមូលធន | **164.072** | **194.533** | **52.874** |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 15.000 | 15.000 | 15.000 |
| - គម្រោងវិនិយោគ | 15.000 | 15.000 | 15.000 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 149.072 | 179.533 | 37.874 |
| ៩.មន្ទីរជំនាញ | **102.094** | **106.129** | **110.345** |
| សរុបចំណាយចរន្ត | **102.094** | **106.129** | **110.345** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 59.930 | 62.927 | 66.073 |
| មិនមែនបន្ទុកបុគ្គលិក | 42.164 | 43.202 | 44.272 |

# គម្រោងថវិកាឆ្នាំ ២០២៣-២០២៥

## តាមក្រសួង-ស្ថាប័ន

ឯកតា:លានរៀល

| បរិយាយ | គម្រោងថវិកាឆ្នាំ ២០២៣ | គម្រោងថវិកាឆ្នាំ ២០២៤ | គម្រោងថវិកាឆ្នាំ ២០២៥ |
|---|---|---|---|
| **១៨. ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** | **161.949** | **168.054** | **174.407** |
| **១.ក្រសួង** | **129.894** | **134.661** | **139.617** |
| **សរុបចំណាយចរន្ត** | **129.894** | **134.661** | **139.617** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 45.862 | 48.155 | 50.563 |
| មិនមែនបន្ទុកបុគ្គលិក | 84.032 | 86.506 | 89.054 |
| ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 69.755 | 71.848 | 74.003 |
| **៩.មន្ទីរជំនាញ** | **32.055** | **33.393** | **34.790** |
| **សរុបចំណាយចរន្ត** | **32.055** | **33.393** | **34.790** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 19.263 | 20.226 | 21.237 |
| មិនមែនបន្ទុកបុគ្គលិក | 12.792 | 13.167 | 13.553 |
| **១៩. ក្រសួងបរិស្ថាន** | **82.229** | **85.757** | **89.449** |
| **១.ក្រសួង** | **35.250** | **36.682** | **38.179** |
| **សរុបចំណាយចរន្ត** | **35.250** | **36.682** | **38.179** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 22.136 | 23.243 | 24.405 |
| មិនមែនបន្ទុកបុគ្គលិក | 13.114 | 13.439 | 13.774 |
| **៩.មន្ទីរជំនាញ** | **46.978** | **49.075** | **51.269** |
| **សរុបចំណាយចរន្ត** | **46.978** | **49.075** | **51.269** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 34.412 | 36.133 | 37.940 |
| មិនមែនបន្ទុកបុគ្គលិក | 12.566 | 12.942 | 13.329 |
| **២០. ក្រសួងអភិវឌ្ឍន៍ជនបទ** | **1.105.639** | **959.509** | **994.699** |
| **១.ក្រសួង** | **1.055.941** | **907.942** | **941.186** |
| **សរុបចំណាយចរន្ត** | **132.938** | **137.233** | **141.673** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 16.355 | 17.172 | 18.031 |
| មិនមែនបន្ទុកបុគ្គលិក | 116.583 | 120.061 | 123.642 |
| **សរុបចំណាយមូលធន** | **923.003** | **770.708** | **799.513** |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 200.000 | 210.000 | 220.000 |
| - គម្រោងវិនិយោគ | 200.000 | 210.000 | 220.000 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 723.003 | 560.708 | 579.513 |
| **៩.មន្ទីរជំនាញ** | **49.698** | **51.567** | **53.512** |
| **សរុបចំណាយចរន្ត** | **49.698** | **51.567** | **53.512** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 19.021 | 19.972 | 20.970 |
| មិនមែនបន្ទុកបុគ្គលិក | 30.677 | 31.596 | 32.542 |

# គម្រោងថវិកាឆ្នាំ ២០២៣-២០២៥
## តាមក្រសួង-ស្ថាប័ន

ឯកតា:លានរៀល

| បរិយាយ | គម្រោងថវិកាឆ្នាំ ២០២៣ | គម្រោងថវិកាឆ្នាំ ២០២៤ | គម្រោងថវិកាឆ្នាំ ២០២៥ |
|---|---|---|---|
| **២១. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | **1.416.358** | **1.419.892** | **1.423.576** |
| **១.ក្រសួង** | **1.362.366** | **1.364.493** | **1.366.710** |
| **សរុបចំណាយចរន្ត** | **1.362.366** | **1.364.493** | **1.366.710** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 25.688 | 26.972 | 28.321 |
| មិនមែនបន្ទុកបុគ្គលិក | 1.336.679 | 1.337.521 | 1.338.389 |
| ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 17.051 | 17.562 | 18.089 |
| **៩.មន្ទីរជំនាញ** | **53.992** | **55.399** | **56.866** |
| **សរុបចំណាយចរន្ត** | **53.992** | **55.399** | **56.866** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 18.071 | 18.975 | 19.924 |
| មិនមែនបន្ទុកបុគ្គលិក | 35.921 | 36.424 | 36.942 |
| **២២. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍** | **155.287** | **186.866** | **219.555** |
| **១.ក្រសួង** | **136.694** | **167.557** | **199.503** |
| **សរុបចំណាយចរន្ត** | **81.075** | **83.930** | **86.893** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 22.581 | 23.710 | 24.895 |
| មិនមែនបន្ទុកបុគ្គលិក | 58.495 | 60.220 | 61.998 |
| ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 8.274 | 8.522 | 8.778 |
| **សរុបចំណាយមូលធន** | **55.618** | **83.628** | **112.610** |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 10.000 | 10.000 | 10.000 |
| - គម្រោងវិនិយោគ | 10.000 | 10.000 | 10.000 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 45.618 | 73.628 | 102.610 |
| **៩.មន្ទីរជំនាញ** | **18.594** | **19.308** | **20.052** |
| **សរុបចំណាយចរន្ត** | **18.594** | **19.308** | **20.052** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 7.853 | 8.246 | 8.658 |
| មិនមែនបន្ទុកបុគ្គលិក | 10.740 | 11.062 | 11.393 |
| **២៣. ក្រសួងធម្មការ និងសាសនា** | **67.586** | **70.513** | **73.577** |
| **១.ក្រសួង** | **25.924** | **26.967** | **28.057** |
| **សរុបចំណាយចរន្ត** | **25.924** | **26.967** | **28.057** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 16.673 | 17.507 | 18.382 |
| មិនមែនបន្ទុកបុគ្គលិក | 9.251 | 9.460 | 9.675 |
| **៩.មន្ទីរជំនាញ** | **41.661** | **43.547** | **45.521** |
| **សរុបចំណាយចរន្ត** | **41.661** | **43.547** | **45.521** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 32.316 | 33.931 | 35.628 |
| មិនមែនបន្ទុកបុគ្គលិក | 9.346 | 9.615 | 9.893 |

# គម្រោងថវិកាឆ្នាំ ២០២៣-២០២៥

## តាមក្រសួង-ស្ថាប័ន

ឯកតា:លានរៀល

| បរិយាយ | គម្រោងថវិកាឆ្នាំ ២០២៣ | គម្រោងថវិកាឆ្នាំ ២០២៤ | គម្រោងថវិកាឆ្នាំ ២០២៥ |
|---|---|---|---|
| **២៤. ក្រសួងកិច្ចការនារី** | **44.783** | 46.347 | 47.977 |
| ១.ក្រសួង | **18.148** | **18.742** | **19.361** |
| សរុបចំណាយចរន្ត | **18.148** | **18.742** | **19.361** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 7.719 | 8.105 | 8.511 |
| មិនមែនបន្ទុកបុគ្គលិក | 10.429 | 10.636 | 10.850 |
| ៩.មន្ទីរជំនាញ | **26.635** | **27.605** | **28.616** |
| សរុបចំណាយចរន្ត | **26.635** | **27.605** | **28.616** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 11.679 | 12.263 | 12.876 |
| មិនមែនបន្ទុកបុគ្គលិក | 14.956 | 15.342 | 15.740 |
| **២៥. ក្រសួងសាធារណការ និងដឹកជញ្ជូន** | **1.855.499** | **1.893.103** | **1.723.990** |
| ១.ក្រសួង | **1.796.058** | **1.831.053** | **1.659.211** |
| សរុបចំណាយចរន្ត | **335.864** | **346.700** | **357.900** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 39.051 | 41.003 | 43.054 |
| មិនមែនបន្ទុកបុគ្គលិក | 296.813 | 305.696 | 314.846 |
| សរុបចំណាយមូលធន | **1.460.194** | **1.484.353** | **1.301.311** |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 300.000 | 300.000 | 320.000 |
| - គម្រោងវិនិយោគ | 300.000 | 300.000 | 320.000 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 1.160.194 | 1.184.353 | 981.311 |
| ៩.មន្ទីរជំនាញ | **59.442** | **62.050** | **64.779** |
| សរុបចំណាយចរន្ត | **59.442** | **62.050** | **64.779** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 41.618 | 43.698 | 45.883 |
| មិនមែនបន្ទុកបុគ្គលិក | 17.824 | 18.352 | 18.895 |
| **២៦. ក្រសួងយុត្តិធម៌** | **170.563** | 177.495 | 184.734 |
| ១.ក្រសួង | **68.439** | **71.042** | **73.758** |
| សរុបចំណាយចរន្ត | **68.439** | **71.042** | **73.758** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 35.388 | 37.158 | 39.016 |
| មិនមែនបន្ទុកបុគ្គលិក | 33.051 | 33.884 | 34.742 |
| ១.១. យុត្តិធម៌ | **38.726** | **40.021** | **41.370** |
| សរុបចំណាយចរន្ត | **38.726** | **40.021** | **41.370** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 14.522 | 15.249 | 16.011 |
| មិនមែនបន្ទុកបុគ្គលិក | 24.204 | 24.773 | 25.359 |

# គម្រោងថវិកាឆ្នាំ ២០២៣-២០២៥

## តាមក្រសួង-ស្ថាប័ន

ឯកតា:លានរៀល

| បរិយាយ | គម្រោងថវិកាឆ្នាំ ២០២៣ | គម្រោងថវិកាឆ្នាំ ២០២៤ | គម្រោងថវិកាឆ្នាំ ២០២៥ |
|---|---|---|---|
| ១.២. តុលាកំពូល | **7.388** | **7.721** | **8.068** |
| សរុបចំណាយចរន្ត | **7.388** | **7.721** | **8.068** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់ម្ហូប) | 5.567 | 5.846 | 6.138 |
| មិនមែនបន្ទុកបុគ្គលិក | 1.821 | 1.875 | 1.930 |
| ១.៣. សាលាឧទ្ធរណ៍ | **17.453** | **18.224** | **19.031** |
| សរុបចំណាយចរន្ត | **17.453** | **18.224** | **19.031** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់ម្ហូប) | 12.406 | 13.026 | 13.677 |
| មិនមែនបន្ទុកបុគ្គលិក | 5.047 | 5.198 | 5.354 |
| ១.៤. ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម | **4.872** | **5.075** | **5.288** |
| សរុបចំណាយចរន្ត | **4.872** | **5.075** | **5.288** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់ម្ហូប) | 2.893 | 3.037 | 3.189 |
| មិនមែនបន្ទុកបុគ្គលិក | 1.979 | 2.038 | 2.099 |
| ៩.មន្ទីរជំនាញ | **102.124** | **106.454** | **110.976** |
| សរុបចំណាយចរន្ត | **102.124** | **106.454** | **110.976** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់ម្ហូប) | 63.323 | 66.489 | 69.813 |
| មិនមែនបន្ទុកបុគ្គលិក | 38.801 | 39.965 | 41.163 |
| **២៧. ក្រសួងទេសចរណ៍** | **77.163** | **80.016** | **82.987** |
| ១.ក្រសួង | **52.334** | **54.171** | **56.080** |
| សរុបចំណាយចរន្ត | **52.334** | **54.171** | **56.080** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់ម្ហូប) | 17.757 | 18.645 | 19.577 |
| មិនមែនបន្ទុកបុគ្គលិក | 34.578 | 35.526 | 36.503 |
| ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 16.530 | 17.026 | 17.537 |
| ៩.មន្ទីរជំនាញ | **24.829** | **25.846** | **26.907** |
| សរុបចំណាយចរន្ត | **24.829** | **25.846** | **26.907** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់ម្ហូប) | 13.627 | 14.308 | 15.024 |
| មិនមែនបន្ទុកបុគ្គលិក | 11.202 | 11.537 | 11.883 |
| **២៨. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** | 100.755 | 103.974 | 107.339 |
| ១.ក្រសួង | **60.070** | **61.488** | **62.969** |
| សរុបចំណាយចរន្ត | **60.070** | **61.488** | **62.969** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់ម្ហូប) | 19.738 | 20.725 | 21.761 |
| មិនមែនបន្ទុកបុគ្គលិក | 40.332 | 40.763 | 41.208 |
| ៩.មន្ទីរជំនាញ | **40.685** | **42.486** | **44.370** |
| សរុបចំណាយចរន្ត | **40.685** | **42.486** | **44.370** |
| បន្ទុកបុគ្គលិក (មិនគិតបញ្ចូលប្រាក់ម្ហូប) | 29.058 | 30.511 | 32.037 |
| មិនមែនបន្ទុកបុគ្គលិក | 11.627 | 11.975 | 12.333 |

# គម្រោងថវិកាឆ្នាំ ២០២៣-២០២៥
## តាមក្រសួង-ស្ថាប័ន

ឯកតា:លានរៀល

| បរិយាយ | គម្រោងថវិកាឆ្នាំ ២០២៣ | គម្រោងថវិកាឆ្នាំ ២០២៤ | គម្រោងថវិកាឆ្នាំ ២០២៥ |
|---|---|---|---|
| **២៩. ក្រសួងធនធានទឹក និងឧតុនិយម** | 833.112 | 1.125.035 | 1.219.215 |
| **១.ក្រសួង** | **794.464** | **1.084.935** | **1.177.605** |
| **សរុបចំណាយចរន្ត** | **123.327** | **127.107** | **131.023** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 21.341 | 22.408 | 23.528 |
| មិនមែនបន្ទុកបុគ្គលិក | 101.986 | 104.700 | 107.495 |
| **សរុបចំណាយមូលធន** | **671.137** | **957.828** | **1.046.582** |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 150.000 | 160.000 | 170.000 |
| - គម្រោងវិនិយោគ | 150.000 | 160.000 | 170.000 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 521.137 | 797.828 | 876.582 |
| **៩.មន្ទីរជំនាញ** | **38.649** | **40.100** | **41.611** |
| **សរុបចំណាយចរន្ត** | **38.649** | **40.100** | **41.611** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 16.306 | 17.121 | 17.977 |
| មិនមែនបន្ទុកបុគ្គលិក | 22.343 | 22.979 | 23.634 |
| **៣០. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** | **301.596** | **311.235** | **321.193** |
| **សរុបចំណាយចរន្ត** | **301.596** | **311.235** | **321.193** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 31.386 | 32.955 | 34.603 |
| មិនមែនបន្ទុកបុគ្គលិក | 270.210 | 278.279 | 286.590 |
| **៣១. អាជ្ញាធរសវនកម្មជាតិ** | **12.921** | **13.494** | **14.093** |
| **សរុបចំណាយចរន្ត** | **12.921** | **13.494** | **14.093** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 9.282 | 9.746 | 10.233 |
| មិនមែនបន្ទុកបុគ្គលិក | 3.639 | 3.748 | 3.859 |
| **៣២. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** | **230.860** | **257.332** | **268.301** |
| **១.ក្រសួង** | **169.655** | **193.380** | **201.474** |
| **សរុបចំណាយចរន្ត** | **154.947** | **159.765** | **164.789** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 62.305 | 65.420 | 68.691 |
| មិនមែនបន្ទុកបុគ្គលិក | 92.642 | 94.344 | 96.097 |
| ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 8.919 | 9.186 | 9.462 |
| **សរុបចំណាយមូលធន** | **14.708** | **33.615** | **36.685** |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 10.000 | 10.000 | 10.000 |
| - គម្រោងវិនិយោគ | 10.000 | 10.000 | 10.000 |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 4.708 | 23.615 | 26.685 |
| **៩.មន្ទីរជំនាញ** | **61.205** | **63.952** | **66.827** |
| **សរុបចំណាយចរន្ត** | **61.205** | **63.952** | **66.827** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 45.554 | 47.832 | 50.223 |
| មិនមែនបន្ទុកបុគ្គលិក | 15.651 | 16.121 | 16.604 |

# គម្រោងថវិកាឆ្នាំ ២០២៣-២០២៥
## តាមក្រសួង-ស្ថាប័ន

ឯកតា:លានរៀល

| បរិយាយ | គម្រោងថវិកាឆ្នាំ ២០២៣ | គម្រោងថវិកាឆ្នាំ ២០២៤ | គម្រោងថវិកាឆ្នាំ ២០២៥ |
|---|---|---|---|
| **៣៣. ស្ថាប័នប្រឆាំងអំពើពុករលួយ** | 43.233 | 45.076 | 47.003 |
| **សរុបចំណាយចរន្ត** | **43.233** | **45.076** | **47.003** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 27.624 | 29.005 | 30.456 |
| មិនមែនបន្ទុកបុគ្គលិក | 15.609 | 16.071 | 16.547 |
| **៣៤. ក្រសួងមុខងារសាធារណៈ** | 55.573 | 57.527 | 59.567 |
| **១.ក្រសួង** | **32.809** | **33.862** | **34.965** |
| **សរុបចំណាយចរន្ត** | **32.809** | **33.862** | **34.965** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 17.637 | 18.518 | 19.444 |
| មិនមែនបន្ទុកបុគ្គលិក | 15.173 | 15.344 | 15.520 |
| **៩.មន្ទីរជំនាញ** | **22.764** | **23.664** | **24.602** |
| **សរុបចំណាយចរន្ត** | **22.764** | **23.664** | **24.602** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 10.876 | 11.420 | 11.991 |
| មិនមែនបន្ទុកបុគ្គលិក | 11.888 | 12.244 | 12.611 |
| **៣៥. ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** | 53.627 | 55.795 | 58.058 |
| **១.ក្រសួង** | **31.504** | **32.791** | **34.135** |
| **សរុបចំណាយចរន្ត** | **31.504** | **32.791** | **34.135** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 18.523 | 19.449 | 20.422 |
| មិនមែនបន្ទុកបុគ្គលិក | 12.980 | 13.341 | 13.713 |
| **៩.មន្ទីរជំនាញ** | **22.123** | **23.004** | **23.923** |
| **សរុបចំណាយចរន្ត** | **22.123** | **23.004** | **23.923** |
| បន្ទុកបុគ្គលិក ( មិនគិតបញ្ចូលប្រាក់រង្វាន់ ) | 10.928 | 11.474 | 12.048 |
| មិនមែនបន្ទុកបុគ្គលិក | 11.195 | 11.530 | 11.875 |
| **ចំណាយផ្សេងៗ** | 927.938 | 965.518 | 1.004.902 |
| - ឧបត្ថម្ភធនដល់រដ្ឋបាលរាជធានី ខេត្ត ( ការប្រគល់មុខងារសុខាភិបាល ) | 792.465 | 823.671 | 856.362 |
| - ឧបត្ថម្ភធនដល់រដ្ឋបាលក្រុង ស្រុក ( ការប្រគល់មុខងារការអប់រំកុមារតូច បឋមសិក្សា និងក្រៅប្រព័ន្ធ ) | 135.473 | 141.847 | 148.540 |